ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិជ្ជា

# ការបំប៉នមាន់សាច់ និងមាន់ពងនៅជនបទ



រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ បណ្ឌិត ខៀវ បូរិន**
**មជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម “សែលអាគ្រិត”**
ទូរស័ព្ទៈ ០២៣ ២២៣៦៤០
**អ៊ីម៉ែលៈ** celagrid@celagrid.org

**កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

## អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈ សម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ ។ គោលគំនិតនៃ បអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុកនិងខេត្ត នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាលនិង ផ្នែកផ្សេងៗទៀត ដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៏កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់ ។ បអប មានលក្ខណៈ ដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប មាននៅតាមស្ថាប័ននានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអបត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា ។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យ របស់ក្រុមការងារ បអប បន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន ។

## បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៏អន្តរជាតិ តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបានខិតខំយ៉ាងពេញ ទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាព មន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្រប តាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថាន ថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង ។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗ ទៀត ។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័តិមាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយក ទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័តិមាន និងបច្ចេក វិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករ ដែលរស់នៅក្នុងតំបន់មាន សក្តានុពលភាពស្របតាមលក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៏ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេស រួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជា ឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋា*ភិបាល ភ្នាក់ងារប្រតិបត្ត*ិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយ ក្តីសង្ឃឹម ។

**រដ្ឋមន្ត្រី**

# មាតិកា


១.សេចក្តីអធិប្បាយ ........................................ វែរ្យវ1 ញ្យ៉ីកមារក ឡ្យត ដថេនដេ។

២. ការណែនាំបច្ចេកទេស ........................................ ៣

២. ការណែនាំបច្ចេកទេស ........................................ ៤

២.១ ហេតុផលនៃការបង្កើត ‘TIP’ នេះ ........................................ ៤

២.២ ការជ្រើសរើសពូជ ........................................ ៥

*២.២.១ មាន់បំប៉ន* ........................................ ៥

*២.២.២ មាន់ពង* ........................................ ៦

២.៣ ទ្រុង និងការគ្រប់គ្រង ........................................ ៧

*២.៣.១ ទ្រុងមាន់* ........................................ ៧

*២.៣.២ ការគ្រប់គ្រង (គំរូចិញ្ចឹមជាក់បន្ទាន់)* ........................................ ១២

៣.៤ ចំណី និងការផ្តល់ចំណី ........................................ ១៦

*២.៤.១ ចំណីលាយនៅផ្ទះកសិករ* ........................................ ១៧

២.៥ ជម្ងឺ និងការការពារ ........................................ ២៤

២,៦ ផលប្រយោជន៍សេដ្ឋកិច្ច ........................................ ២៨

២.៧ ផលប៉ះពាល់លើបរិស្ថាន ........................................ ៣១

៣.ការណែនាំលើការងារផ្សព្វផ្សាយ ........................................ វែរ្យវ1 ញ្យ៉ីកមារក ឡ្យត ដថេនដេ។

៣.១ វិធីសាស្ត្រនៃការផ្សព្វផ្សាយ ........................................ ៣២

៣.២ ថវិកាសម្រាប់ការធ្វើបង្ហាញ ........................................ ៣៥

៣.៣ កន្លែងរកឯកសារបន្ថែម ........................................ ៣៧

៣.៤ យែនឌ័រ ........................................ ៣៧

## ១-សេចក្តីអធិប្បាយ

### គោលបំណង និងផលប្រយោជន៍

ទិសដៅសំខាន់ៗសម្រាប់ ‘TIP’ ការបំប៉នមាន់សាច់ និងមាន់ពងនៅជនបទ មានដូចខាងក្រោមនេះ

- ដើម្បីផ្តល់ជាជម្រើសអាហាររូបត្ថម្ភ និងប្រភពចំណូលជាប្រាក់ដល់គ្រួសារជនបទ ។
- ផ្តល់ដល់អ្នកផ្សព្វផ្សាយនូវការណែនាំបច្ចេកទេសល្អៗនានាសម្រាប់បច្ចុប្បន្នកាល និងការផ្សព្វផ្សាយ ដើម្បីកែលំអផលិតកម្មមាន់ស្រុក និងប្រាក់ចំណេញនៅតំបន់ជនបទ ។

## លក្ខណៈវិនិច្ឆ័យបច្ចេកទេសសមស្រប

ខាងក្រោមនេះ ជាលក្ខខណ្ឌចាំបាច់រួមបញ្ចូល សង្គម អាកាសធាតុ/បរិស្ថាន និងតម្រូវការសេដ្ឋកិច្ច សម្រាប់ការអនុវត្តន៍ ‘TIP’ នេះ ដើម្បីសំរេចជោគជ័យលើ ទិសដៅលើកឡើងខាងលើៈ

### យេនឌ័រ

- ស្ត្រី និងបុរសអាចចូលរួមក្នុងការអនុវត្តន៍ ‘TIP’ នេះ តែដោយសារការចិញ្ចឹមមាន់នេះ ជាមុខរបរនៅក្បែរផ្ទះសំបែង ដូច្នេះអទិភាពគួរផ្តល់ដល់ស្ត្រី ដោយសារពួកគេមានលទ្ធភាពផ្សារភ្ជាប់ការងារនេះជាមួយការងារផ្ទះសំបែង ។ ការអនុវត្តន៍ ‘TIP’ នេះ អាចជួយដល់ស្ត្រី ក្នុងការបង្កើនចំណូល ដើម្បីទ្រទ្រង់ដល់គ្រួសាររបស់គេ ជាពិសេសការកែលំអអាហាររូបត្ថម្ភ ដល់កុមារ និងប្រាក់សម្រាប់ឱ្យកូនបង់ថ្លៃសាលា និងការចំណាយផ្សេងៗទៀត ។

### អាកាសធាតុ/ទឹក

- មិនមានការព្រួយបារម្ភខ្លាំង ទៅលើអាកាសធាតុទេ ដោយសារមាន់ដែលបានរើសមកចិញ្ចឹមក្នុង ‘TIP’ នេះ ជាពូជមាន់ស្រុក ដែលមានការធន់ និងអាកាសធាតុនៅប្រទេសកម្ពុជា ។ ទោះបីយ៉ាងណាក៏ដោយ ការបង្កើតបរិយាកាសសមស្របនៅរដូវប្រាំង (មិនា-មេសា) ដោយមានជាម្លប់ជាការប្រសើរសម្រាប់មាន់ ។ ដើមល្ហុងប្រេងត្រូវបានចាត់ទុកថា ជាម្លប់បៃតងល្អប្រសើរ ។ ការការពារមិនឱ្យភ្លៀងសាចឆ្លងទ្រុងមាន់ពង ជាវិធីមួយប្រសើរ ដើម្បីជៀសវាងការខូចខាតស៊ុត ។ គួរចងចាំថា មាន់មានការលូតលាស់បានល្អនៅពេលសីតុណ្ហភាព ស្ថិតនៅក្រោម ៣០ អង្សារសេ ។

- បរិមាណទឹកតិចតួច ដងពីអណ្តូង អាចគ្រប់គ្រាន់សម្រាប់មាន់ផឹក ។ តែប្រសិនណាកសិករ ត្រូវផលិតចំណីមួយចំនួនដូចជា ចកបាយទា និងត្រកួន ជាប្រូតេអ៊ីន សម្រាប់មាន់ ពួកគេត្រូវការ ទឹកសម្រាប់ស្រោចស្រព និងបន្ថែមក្នុងស្រះចកនៅរដូវប្រាំង ។

## ភូមិសាស្ត្រ

- បអប នេះ អាចអនុវត្តនៅគ្រប់ទីកន្លែងទាំងអស់ នៃប្រទេសកម្ពុជា គ្រាន់តែពិចារណា ទៅលើធនធានចំណីអាហារដែលមាន ឬដែលត្រូវដាំស្របទៅតាម លក្ខខណ្ឌជាក់លាក់របស់ តំបន់ភូមិសាស្ត្រនិមួយៗ ។ ផ្ទុយទៅវិញ សម្រាប់ភូមិដែលលិចទឹកនៅរដូវវស្សា អាចមានការ លំបាកសម្រាប់អនុវត្ត បអប នេះ តែអាចរៀបចំបាននៅរដូវទឹកសំរក ។

## ទំហំទីកន្លែង

- ទ្រុងដែលមានទំហំ ២,៥ គុណ ៣ ម៉ែត្រ អាចដាក់ មាន់ចំនួន ៥០ក្បាល សម្រាប់ដេកពេលយប់ និងផ្នែកមួយសម្រាប់មាន់ពង ។ តែដោយសារ ‘TIP’ នេះ រៀបចំឡើងដោយបង្ខាំងមាន់ នៅទីកន្លែងមួយ ដូច្នេះផ្ទៃដីទំហំ ៥០-៦០ ម២ (៥-៦ គុណ ១០ ម៉ែត្រ) ទៀតសម្រាប់ ធ្វើជារបង ។

## តម្រូវការពលកម្ម

- មនុស្សម្នាក់នៅក្នុងគ្រួសារ ជាពិសេសស្ត្រី អាចចំណាយពេល ១-២ម៉ ក្នុង១ថ្ងៃ ដាក់ទឹក-ចំណី សំអាត និងការងារបន្ទាប់បន្សំតិចតួចទៀតអាចគ្រប់គ្រាន់សម្រាប់មេមាន់ ៥ក្បាល ។ អាចតម្រូវការពលកម្មច្រើន នៅពេលសាងសង់ទ្រុង ផលិតចំណី និងរៀបចំរណ្តៅ សម្រាប់ផលិត ចកបាយទា ឬថ្នាលត្រកួន ។ល។ នៅពេលចាប់ផ្តើម ។

## ស្ថានភាពសេដ្ឋកិច្ចកសិករ

- ការចិញ្ចឹមមាន់មានចាប់អារម្មណ៍ពិសេសដល់មនុស្ស ដែលមានមធ្យោបាយ និងធនធានតិចតួច ដោយសារ ត្រូវការចំណាយតិចសម្រាប់អនុវត្ត ។
- ដោយចាត់ទុកថា កសិករជ្រើសរើសនេះ បានចូលរួមរួចទៅហើយនៅក្នុង ‘TIP’ សម្រាប់កូនមាន់១-៤៥ថ្ងៃ ដូច្នេះកសិករនេះមានកូនមាន់រួចតែគេនៅត្រូវការប្រាក់ចំនួន ៣៧៧.០០០រៀល សម្រាប់ការចំណាយផ្សេងៗទៀត ដូចជា ចំណី ទ្រុង របង ថ្នាំ និងវ៉ាក់សាំង ។ល។ ការចំ ណាយ អាចកាត់បន្ថយនៅពេលដែលកសិករប្រើប្រាស់ចំណីដែលផលិតនៅក្នុងកសិដ្ឋានរបស់ខ្លួន

**អនុសាសន៍ផ្សេងទៀត**

- កសិករត្រូវប្រើប្រាស់ចំណី និងសំភារៈសាងសង់ដែល មាននៅក្នុងកសិដ្ឋាន ឬផលិតនៅក្នុង កសិដ្ឋាន ដើម្បីបង្កើនប្រាក់ចំណេញ ។ ជាឧទាហរណ៍ ការដាំដំណាំដូចជា ដំឡូងឈើ ត្រកួន ចកបាយទា មរម្យ ផ្តល់ជាចំណីប្រូតេអ៊ីនបន្ថែមដល់ការចិញ្ចឹមមាន់ ។
- ប្រើប្រាស់សណ្តែកសៀងគ្រាប់ដោយសារម្សៅត្រីមិនអាចធានាគុណភាពល្អ ។

---

## ២. ការណែនាំបច្ចេកទេស

### ២.១ ហេតុផលនៃការបង្កើត ‘TIP’ នេះ

តាមទំលាប់ មាន់ត្រូវបានចិញ្ចឹមលែងអោយដើររកចំណីខ្លួនវា ។ ការចិញ្ចឹមមាន់នៅក្នុងប្រព័ន្ធ គឺកសិករទទួលផលពីមាន់ដែលនៅសេសសល់ ពីការស្វះស្វែងរកចំណីដោយខ្លួនវា ពីសត្វផ្សេងៗដែលជាសត្រូវវា និងជម្ងឺផ្សេងៗ ។ តែនៅពេលដែលកសិករមានបំណងយកការចញ្ចឹមមាន់នេះជាជំនួញមួយនោះ ពួកគេត្រូវរៀបចំខ្លួនជាស្រេចក្នុងផ្តល់ការយកចិត្តទុកដាក់ និងការថែទាំរួមបញ្ចូលទាំងទ្រុង និងការផ្តល់ចំណី ។ នៅ ពេលគ្រប់គ្រងបានល្អ កសិករអាចទទួលបានមាន់ចំនួន ៣០-៤០ ក្បាល សម្រាប់បំប៉ននិមួយៗ ពីមេមាន់ចំនួន ៥ ក្បាល ។ ផលិតកម្មមាន់មួយក្រុមតូចនេះ មិនតម្រូវការតំរិតបច្ចេកទេសដូចការចិញ្ចឹមជាលក្ខណៈឧស្សាហកម្មនោះឡើយ ប៉ុន្តែមាន់មួយក្រុមតូចនេះ ជាធនធានសំខាន់សម្រាប់គ្រួសារកសិករ ជាអាហារ និង ប្រាក់ ចំណូល ដោយមិនចាំបាច់ចំណាយពេលវេលា និងធនធានច្រើន ។

ទោះបីជាមាន់មួយក្រុមតូចក៏ដោយ ក៏កសិករត្រូវការវិនិយោគទៅលើកូនមាន់ ទ្រុង និងចំណីអាហារសម្រាប់ការបំប៉នរយៈពេល ៥ខែ គិតចាប់ពីថ្ងៃញាស់រហូតដល់ពេលលក់ ។ នៅពេលមាន់ញីត្រូវបានទុកសម្រាប់យកពង នឹងត្រូវការទុនថែមទៀតសម្រាប់ចំណីរបស់មាន់ពង ។ នៅក្នុង ‘TIP’ នេះ នឹងផ្តោតទៅលើការលូតលាស់ និងការកែលំអនានាសម្រាប់មាន់ចិញ្ចឹមយកសាច់ ឬពង ឬយកពង និងសាច់រួមគ្នា អាស្រ័យទៅលើតម្រូវការ លទ្ធភាព និងស្ថានភាពទីផ្សារ ។ ក្នុងការបន្តពីមាន់ជំទង់ទៅមាន់សម្រាប់យកពង តម្រូវការវិនិយោគទុនថែមទៀត តែចំណាយពេលតិចសម្រាប់ទទួលបានចំណូលមកវិញ ដោយសារមាន់ផ្តល់មកវិញជាប្រចាំ សម្រាប់លក់យកប្រាក់មកវិញ ។ ជាទូទៅនៅក្នុងចំនួន ៣០-៤០ ក្បាល បំប៉ននេះ អាចមាន ៥០% ជាមាន់ឈ្មោល ដែលកសិករអាចលក់វាជាមាន់សាច់ ហើយយកប្រាក់នោះមកបន្តចំណាយលើ មាន់ពង ។

‘TIP’ នេះ នឹងផ្តល់ព័តិមានបច្ចេកទេស និងមូលដ្ឋានដល់អ្នកផ្សព្វផ្សាយ និងមនុស្សពាក់ព័ន្ធផ្សេងៗ ទៀត ដើម្បីជួយកសិករបង្កើនផលិតកម្មមាន់ដោយធ្វើការកែលំអទៅលើការចិញ្ចឹមតាមលក្ខណៈបុរាណនោះ។ នៅពេលមាន់ត្រូវបានចិញ្ចឹមដាក់ទ្រុង មាន់ទាំងនោះនឹងពឹងផ្អែកទាំងស្រុងទៅលើម្ចាស់វាក្នុងការផ្តល់ចំណី និងទឹកសម្រាប់ការលូតលាស់របស់វា និងផលិតស៊ុត ។

## ២.២ ការជ្រើសរើសពូជ

អស់រយៈពេលជាយូរណាស់មកហើយ កសិករបានចិញ្ចឹមមាន់ពូជស្រុក ដែលជាទូទៅមានទំហំតូច មធ្យម និងធំ មានពណ៌ខ្មៅ និងពណ៌ចំរុះ បណ្តើរកូនរយៈពេលខ្លី និងវែង មានសរសៃខ្លី និងវែង មានជើងវែង និងខ្លី ។ល។ ផ្ទុយមកវិញការជ្រើសរើសពូជដែលកសិករធ្លាប់ធ្វើបានផ្អែកលើ ១)ពូជដែលមាននៅក្បែរ អាចរកបាន ២)ជាអំណោយ និង៣)ជាមាន់ដែលនៅសេសសល់ក្រោយជម្ងឺផ្ទុះ ។ ពូជមាន់ក្នុងស្រុកនេះ អាចសម្របសម្រួល ទៅនឹងអាកាសធាតុ និងបរិស្ថាន ហើយមានភាពរហ័សរហួនដែលធ្វើឱ្យសត្វផ្សេងទៀត ដូចជាឆ្មារ ឆ្កែ មិនងាយចាប់ជាចំណី ។ មេមាន់ពូជក្នុងស្រុកជាទូទៅជាមេមាន់ល្អ ទោះបីជាមានកូនមាន់ជា ច្រើនត្រូវងាប់ដោយសារសត្វផ្សេងៗ និងជម្ងឺ មុនពេលពួកគេពេញវ័យ ។ សំខាន់ទៅទៀតនោះមានមនុស្ស ច្រើន ដែលចាត់ថា មាន់ពូជក្នុងស្រុកមានរស់ជាតិឆ្ងាញ់ ។

### ២.២.១ មាន់មេបំបៅ

កសិករជាទូទៅមិនមានឱកាសច្រើនក្នុងការជ្រើសរើសពូជទេ នៅក្នុងប្រព័ន្ធផលិតកម្មជាទំលាប់នោះ ដោយសារមាន់ភាគច្រើនត្រូវបានងាប់ដោយសារការផ្ទុះឡើងនៃជម្ងឺ ឬលក់មុនការផ្ទុះឡើងនៃជម្ងឺ ។ ផ្ទុយ ទៅវិញ ការចាក់ថ្នាំការពារអាចសង្ឃឹមថា អាត្រារស់រានអាចមានរហូតដល់ ៧០-៨០% ដែលធ្វើឱ្យកសិករ មានលទ្ធភាពធ្វើការសង្កេតយូរទៅលើលក្ខណៈរបស់មាន់ មុននឹងធ្វើការសំរេចចិត្តជ្រើសរើសសម្រាប់បន្តពូជ ហើយលក្ខណៈដែលអាចពិនិត្យមើលមាន:

- លូតលាស់លឿន
- ពងច្រើនក្នុងមួយវគ្គ ឬមួយឆ្នាំ
- ភ្ញាស់កូនបានច្រើន
- ថែទាំកូនបានល្អ និង
- បណ្តើរកូនរយៈពេលខ្លី ។

ទោះបីយ៉ាងណាក៏ដោយ លក្ខណៈនេះមិនមែនត្រឹមតែប៉ុណ្ណោះទេ កសិករអាចពិនិត្យមើលពីមួយឆ្នាំ ទៅមួយឆ្នាំដោយផ្អែកទៅលើការសង្កេតផ្សេងទៀត អាស្រ័យតាមទីផ្សារ:

- ពណ៌របស់រោម

- ពណ៌របស់ស្បែក
- ពណ៌របស់ជើង
- ពណ៌របស់សំបកពង

ជាទូទៅមាន់ដែលមានជើង និងស្បែកពណ៌លឿង មានការនិយមពីអ្នកទិញនៅទីផ្សារ ។ តែមាន់សំឡីដែលមានរោមពណ៌ស ស្បែក ជើង និងឆ្អឹងខ្មៅ មានការនិយមសម្រាប់ជាម្ហូបនៅពេលរៀបអាពាហ៍ពិពាហ៍ ។ កសិករអាចចិញ្ចឹមមាន់គ្រប់ប្រភេទ ក្នុងករណីនេះ អ្នកផ្សព្វផ្សាយត្រូវមានលទ្ធភាពជួយផ្តល់ការណែនាំដល់កសិករឱ្យរៀបចំផែនការ ថាតើមានប្រភេទណាមួយត្រូវលក់នៅពេលមានតម្រូវការខ្ពស់នៅក្នុងឆ្នាំនិមួយៗ ដែលធ្វើឱ្យពួកគេអាចរកចំណូលច្រើន ។

ដោយនៅប្រទេសកម្ពុជាគ្មានស្ថានីយ៍ជ្រើសរើសពូជមាន់ជាផ្លូវការដែលអាចផ្តល់ជាអនុសាសន៍ទៅលើពូជដែលមានសក្តានុពលសម្រាប់យកសាច់ ឬស៊ុត ឬសាច់ និងស៊ុតផងនោះ បទពិសោធន៍ និងការសង្កេតដែល លើកឡើងខាងលើ អាចសមស្របសម្រាប់ស្ថានភាពបច្ចុប្បន្ន ។

### ២.២.២ មាន់ពង

នៅក្នុងមាន់ពូជក្នុងស្រុក គ្មានមាន់ដែលពងច្រើននោះទេ ។ ជាទូទៅមេមាន់ស្រុកពងពី ១៥-២០គ្រាប់ក្នុងមួយវគ្គ ហើយចាប់ផ្តើមក្រាបពង ។ ទោះយ៉ាងណាក៏ដោយ មានមេមាន់ដែលបណ្តើរកូនរយៈខ្លី ធ្វើឱ្យវាអាចពងច្រើនគិតក្នុងរយៈពេលមួយឆ្នាំ ហើយមេមាន់ទាំងនោះ ច្រើនជាមាន់ដែលមានទំហំតូច (មាន់ចែរ មាន់ស្គួយ) ។ តែគួរចាំថា មាន់ស្រែដែលចិញ្ចឹមលែង តែងតែពងនៅតាមព្រៃ គុម្ពស្មៅដែលធ្វើ ឱ្យមានការ លំបាកក្នុងការប្រមូលពង ។

ស៊ុតរបស់មាន់ពូជក្នុងស្រុកមានតម្លៃថ្លៃជាងពងមាន់នៃពូជនាំចូល។ ករណីនេះកើតឡើងអាចដោយ សារការផ្គត់ផ្គង់មិនគ្រប់គ្រាន់ និងជម្រើសរបស់អ្នកហូប ជាពិសេសសម្រាប់ដាក់ក្នុងទឹកផ្លែឈើក្រឡុកនៅ តាម ទីប្រជុំជន។ កសិករជាទូទៅចិញ្ចឹមមាន់មេសម្រាប់យកពងភ្ញាស់ជាកូន ដែលអនុញ្ញាតឱ្យគេបន្តផលិត មាន់សាច់ដែលជាហេតុធ្វើឱ្យការផ្គត់ផ្គង់ពងមាន់ស្រុកមិនបានគ្រប់គ្រាន់ ។

ការផលិតពងនៃមាន់ក្នុងស្រុកអាចកើនឡើងក្នុងមួយឆ្នាំ ដោយអនុវត្តតាមការគ្រប់គ្រងដូចខាងក្រោម:

- យកពងមាន់ចេញ រៀងរាល់ថ្ងៃដោយទុកតែពងមួយគ្រាប់នៅក្នុងសំបុក
- ជ្រលក់មេមាន់ក្នុងទឹក២ដងក្នុងមួយថ្ងៃនៅពេលដែលវាចាប់ផ្តើមក្រាបពង ហើយបង្ខាំងក្នុងទ្រុង៤-៥ ថ្ងៃ

- ផ្ដល់ចំណីឱ្យបានគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព និងទឹក ហើយផ្ដល់មេរៀសំបកខ្យងខ្ចៅនៅក្នុងចំណី ដែលជាប្រភពសម្រាប់បង្កើតសំបកពង ។

## ២.៣ ទ្រុង និងការគ្រប់គ្រង

នៅក្នុងប្រព័ន្ធចិញ្ចឹមមាន់បុរាណ មាន់មិនត្រូវបានផ្ដល់ការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់នោះទេ ។ មាន់ត្រូវឱ្យដេកនៅលើដើមឈើ នៅក្រោមផ្ទះ ហើយមានជួនកាលនៅលើដំបូលផ្ទះ តែការចិញ្ចឹមនេះសង្កេតឃើញមានភាពជោគជ័យក្នុងការចិញ្ចឹមនៅពេលដែលទីតាំងនៃកន្លែងចិញ្ចឹមស្ថិតនៅដាច់តែឯកឯង ។ ប៉ុន្តែ ស្ថានភាពនេះ មិនមាននៅគ្រប់ទីកន្លែងនោះទេ ដោយសារជាទំនៀមទំលាប់ ផ្ទះកសិករច្រើនសាងសង់ នៅក្បែរគ្នា ដើម្បីជួយគ្នាទៅវិញទៅមកក្នុងករណីមានការបន្ទាន់ ។

ទោះបីជាពូជក្នុងស្រុកអាចរស់រានមានជីវិត និងសំរបខ្លួនវាទៅតាមលក្ខខណ្ឌធម្មជាតិ និងជនបទ មាន់ ពូជនេះជាទូទៅមិនសមស្របសម្រាប់ការចិញ្ចឹមដាក់ទ្រុងទាំងស្រុងនោះទេ ដោយសារពួកវាសកម្ម និងមាន ភាពរីករាយនៅពេលពួកវាអាចនៅផ្ទាល់ដី និងបរិស្ថានជុំវិញវា មានការផ្ដល់ចំណី និងទឹកស្អាត មានគុណភាព ហើយករណីនេះអាចធ្វើឱ្យវាឆាប់មានលូតលាស់ល្អ ហើយក៏ផលិតស៊ុតបានច្រើន និងមានគុណភាពល្អទៀត ផង ។

ខាងក្រោមនេះ ជាការគំរូមួយចំនួន ដែលអាចជាការជួយដល់អ្នកផ្សព្វផ្សាយ ផ្ដល់ដំបូន្មានដល់កសិករ ដើម្បីសាងសង់ទ្រុងមាន់ក្នុងការអនុវត្តន៍ ‘TIP’ នេះ ។

### ២.៣.១ ទ្រុងមាន់

ទ្រុងមាន់មានសារៈប្រយោជន៍ណាស់សម្រាប់មាន់ ដោយសារវាមិនត្រឹមតែផ្ដល់សន្តិសុខ និងសុវត្ថិភាព អាច ដល់មាន់នៅពេលយប់ពីចោរកម្ម និងសត្វកាចសាហាវនោះទេ ប៉ុន្តែវាបានបង្កើតលក្ខខណ្ឌចាំបាច់មួយ ចំនួន ដើម្បីធ្វើការងារសំខាន់ៗមួយចំនួនដូចជា:

- ការចាក់វ៉ាក់សាំងការពារមាន់
- ត្រួតពិនិត្យមាន់តាមរយៈការរាប់មាន់នៅរាល់ពេលល្ងាច
- ផ្ដុំលាមកមាន់នៅកន្លែងមួយ ងាយស្រួលប្រមូលធ្វើជី និង
- ងាយចាប់មាន់នៅពេលចង់បរិភោគ និងលក់ ។

ទីតាំងសមស្របសម្រាប់សង់ទ្រុងមាន់ ត្រូវស្ថិតនៅក្បែរផ្ទះការពារពីចោរ និងសត្វសាហាវផ្សេងទៀត ដូចជា ឆ្កែ ឆ្មារនៅពេលយប់ ។ ទ្រុងមាន់ត្រូវមានលក្ខណៈសាមញ្ញ និងសាងសង់សោយប្រើប្រាស់សំភារៈមាន នៅក្នុងកសិដ្ឋាន និងភូមិ ។ សំភារៈទាំងនោះមានៈ

- សសរឈើ
- បង្កង់ ឃ្មៀបជញ្ជាំង
- កូនឈើមូល ត្រែង ឬបន្ទះឬស្សី
- ស្លឹកត្នោតសម្រាប់ប្រក់
- ដែកគោល និងលួស

**ចំណាំ**

- ជាសំណូមពរដំបូលទ្រុងត្រូវប្រក់ស្បូវ ឬស្លឹកត្នោតដើម្បីបង្កឱ្យមានសីតុណ្ហភាពត្រជាក់នៅទី នោះជាពិសេសនៅរដូវប្រាំង ។
- ក្នុងករណីប្រក់សង្កសី ឬដំបូលដែកដែលមាននៅក្នុងកសិដ្ឋានស្រាប់នោះ ការធ្វើឱ្យមានម្លប់ឈើជាកត្តាចាំបាច់ ។

○ ដោយចាត់ទុកថាកសិករម្នាក់ចិញ្ចឹមមេមាន់ចំនួន ៥ក្បាល អាចផលិតកូនចំនួន ១២០-១៦០ក្បាល ក្នុង មួយឆ្នាំ ក្នុងលក្ខខណ្ឌដែលកសិករនេះអនុវត្តតាមការគ្រប់គ្រង ថែទាំបានល្អ និងការផ្តល់ចំណី-ទឹក ។ ហេតុដូចនេះ គាត់អាចទទួលបានមាន់ចំនួន ៣០-៤០ក្បាល ក្នុងមួយវគ្គបំប៉នយកសាច់ ។ ក្នុងករណីនេះ គាត់ត្រូវការទ្រុងដែលមានទំហំ ២,៥ គុណ ៣ម៉ែត្រ សម្រាប់ជាជំរកដល់មាន់នៅពេលយប់ និងផ្នែកមួយ តូចសម្រាប់ដាក់សំបុកមាន់ពង ។

○ កសិករអាចជ្រើសរើសយកគំរូមួយដែលផ្តល់នៅខាងក្រោម អាស្រ័យទៅតាមការចូលចិត្ត ។ គំរូទីមួយ (រូបភាព ១ក និង ខ) សបស្រុបសម្រាប់ការ ចិញ្ចឹមមាន់យកសាច់ដោយសារមានខ្យល់ចេញចូល ល្អ ហើយ គំរូទី ២ (រូបភាព ២ក និងខ) សមស្របណាស់សម្រាប់មាន់ពង និងក្រាបពង ដោយសារទ្រុង ប្រភេទនេះ មានការការពារពីភ្លៀងសាច ។

○ មាន់ត្រូវបានការពារពីខ្យល់ខ្លាំង ឬភ្លៀងសាច ។ ការងារនេះ អាចធ្វើទៅបានដោយគ្រាន់តែភ្ជួរកន្ទេលចាស់ ប៉ាវ ឬសំភារៈផ្សេងទៀតដែលអាចបាំងភ្លៀងបាន ។




គំរូ ១ ទ្រុងមាន់ដំបូលកាត់សម្រាប់មាន់បំប៉ន




រូបភាព ១កៈ ទ្រុងមាន់តូចសាមញ្ញធ្វើបង្ហាញដល់អ្នកសម្របសម្រួលថ្នាក់ស្រុក នៅខេត្តតាកែវ




រូបភាព ១ខៈ សំណាញ់ជ័រអាចប្រើប្រាស់សម្រាប់បាំងជាជញ្ជាំង




គំរូ ២ ទ្រុងមាន់មានដំបូលកន្ដាំង



រូបភាព ២ក: ជញ្ជាំងទ្រុងមាន់អាចបាំងដោយសំណាញ់ ជ័រ




រូបភាព ២ខ: ទ្រុងអាចសាមញ្ញតែអាចការពារគ្រប់គ្រាន់ពីការសាចភ្លៀង

នៅក្នុងប្រព័ន្ធចិញ្ចឹមមាន់បុរាណ កសិករភាគច្រើនមិនបានបែងចែកកូនមាន់ចេញ កន្លែងមាន់ដេក និងសំបុក ពង នោះទេ ។ គ្មានការបែងចែកនេះ អាចរំខានដល់មេមាន់ក្រាបពង ។ ថែមលើនេះអាចកាត់បន្ថយចំនួនកូន មាន់

ញ៉ាស់ដោយសារលាមកមាន់ធ្លាក់ទៅក្នុងសំបុកប៉ះពាល់ដល់ពងមាន់ ។ ដើម្បីកាត់បន្ថយការចំណាយទៅ លើការសាងសង់ទ្រុងមាន់ពងមួយទៀត កសិករអាចបិទផ្នែកម្ខាងសម្រាប់មាន់ពង (គំរូទី ៣) ។




គំរូ ៣ ទ្រុងមាន់មើលខាងក្នុង

កន្លែងមាន់ដេកត្រូវសង់កំពស់ ០,៨ម- ១ម ដែលធ្វើឱ្យមានកំពស់ស្រឡះអាចចូលទៅសំអាត និង ប្រមូលលាមក ។ ក្រៅពីនេះ ប្រសិនបើទ្រុងមានសុវត្ថិភាព អង្រុតក្រុងកូនមាន់អាចដាក់បញ្ចូលទៅក្នុងទ្រុង នោះផងដែរ តែកសិករមិនត្រូវដាក់អង្រុត និងកូនមាន់នៅក្រោមកន្លែងមាន់ធំដេកនោះទេ ព្រោះមាន់ធំអាច ជុះអាចម៍លើកូនមាន់ ។

### ២.៣.២ ការគ្រប់គ្រង (គំរូចិញ្ចឹមដាក់បង្ខាំង)

ដូចបានដាក់លើកឡើងខាងលើ ពីរបៀបសាងសង់ទ្រុងមាន់ និងគំរូផ្សេងៗ ដែលបានដាក់បញ្ចូលទៅក្នុង 'TIP' នេះ ជាឧទាហរណ៍សម្រាប់កសិករជ្រើសរើសអាស្រ័យទៅតាមចំណង់ចំណូលចិត្ត និងតំបន់ដែល 'TIP' នេះ ត្រូវយកទៅតប្រើប្រាស់ ។ ពេលនេះ នឹងពិភាក្សាពីការងារគ្រប់គ្រង លក្ខខណ្ឌតម្រូវការ ប្រភេទបង្ខាំងសត្វដែលត្រូវរៀបចំសម្រាប់ផលិតកម្មមួយមានប្រសិទ្ធិភាព ។ ការធ្វើឱ្យប្រសើរឡើងដល់ការគ្រប់គ្រង នឹងធ្វើឱ្យការទទួលផលកើនដល់អប្បបរមា សម្រាប់កសិករ ឬអ្នកផលិតមាន់ ។

នៅក្នុងប្រព័ន្ធចិញ្ចឹមតាមលក្ខណៈបុរាណ ឬលែងឱ្យដើររកចំណី កសិករភាគគិតថាមាន់អាចរកចំណី ដោយខ្លួនវា តម្រូវការការថែទាំតិចតួច និងផលទទួលពីមាន់នៅសេសសល់ពីការស្លាប់ ។ ផលិតកម្ម ប្រភេទនេះត្រូវបានអនុវត្តជាច្រើនជំនាន់ណាស់មកហើយ។ បច្ចុប្បន្ននេះមានផលល្អ និងមិនល្អពីផលិតកម្ម ប្រភេទនេះ ដោយយោលទៅកត្តានានាដែលបានលើកឡើងខាងលើ ។ ជាបទពិសោធន៍នៅពេលដែល កសិករយកចិត្តទុកដាក់ទៅលើផលិតកម្មមាន់នេះ ដោយអនុវត្តការបង្ខាំង ផ្តល់ចំណី និងទឹកស្អាត កសិករនេះជាទូទៅទទួលបានប្រាក់ចំណូលល្អប្រសើរ ។ ការចិញ្ចឹមមាន់បង្ខាំង ឬ ពាក់កណ្តាលបង្ខាំង មានផលប្រយោជន៍ច្រើនលើការ ចិញ្ចឹមមាន់តាមលក្ខណៈបុរាណ ឬចិញ្ចឹមលែងៈ

- ការពារជម្ងឺបានប្រសើរ
- មានការបាត់បង់តិចតួចដោយសារចោរលួច ឬសត្វចាប់ស៊ី
- គ្មានការរំខានដល់ការដាំដំណាំ និងបន្លែ
- ងាយស្រួលប្រមូលស៊ុត
- ងាយស្រួលពិនិត្យមើលមាន់ជាប្រចាំ
- ងាយស្រួលចាប់មាន់សម្រាប់ធ្វើម្ហូប និងលក់
- ងាយស្រួលប្រមូលលាមកសម្រាប់ជាជីដាក់បន្លែ ។

- កសិករដែលមានផ្ទះដាច់ៗគ្នា ពួកគាត់អាចមិនចាំបាច់ធ្វើរបងបង្ខាំងដោយសារទីតាំងនោះអាចព័ទ្ធជុំវិញទៅដោយប្រឡាយ ទឹក និងវាលស្រែ (រូបភាពទី ៣) ។ ទោះបីយ៉ាងណាក៏ដោយ ក៏នៅមានបញ្ហា មួយចំនួន និងការងារដែលត្រូវធ្វើដែរ ។

  - មាន់អាចបំផ្លាញថ្នាលសំណាប ប្រសិនបើគ្មាននរណាម្នាក់នៅក្នុងគ្រួសារចាំមើលនៅពេលសាបរួច ជាពិសេសនៅដំណាក់កាលស្រូវដុះ ។

- សួនបន្លែត្រូវបានធ្វើរបងព័ទ្ធដើម្បីការពារមាន់ចូលក្នុងសួន ។
- សត្វផ្សេងអាចចាប់មាន់ជាចំណី ។




រូបភាព ៣ ផ្ទះដាច់តែឯង អាចមិនចាំបាច់របងបិទ ប៉ុន្តែត្រូវការទ្រុងមួយសម្រាប់មាន់ដេកពេលយប់



រូបភាព ៤ ការដាក់ទ្រុងបង្ខាំងមាន់ជាការចាំបាច់ នៅពេលផ្ទះជាប់ៗគ្នា

- នៅពេលដែលផ្ទះអ្នកភូមិនៅជាប់ៗគ្នា ការបង្ខាំងមាន់ក្នុងទ្រុង ជាការចាំបាច់ ។ ទីកន្លែងធ្វើរបងបង្ខាំងអាចធ្វើនៅក្បែរផ្ទះ(រូបភាព៤) និងនៅព័ទ្ធជុំវិញដោយដើមឈើហូបផ្លែ ដូចជាដើមចេក (រូបភាព ៥) ។ ការបង្ខាំងក្នុងទ្រុងនឹងជួយដល់កសិករដើម្បីទទួលបានផលប្រយោជន៍នានាដូចបានលើកឡើងខាងលើ ។



រូបភាព ៥ ទីកន្លែងបង្ខាំងអាចធ្វើឡើងជុំវិញដើម ឈើហូបផ្លែដូចជាចេក ។ល។




រូបភាព ៦ រនាបឫស្សីអាចប្រើប្រាស់ក្នុងការធ្វើរបងបង្ខាំងផងដែរ ។

- របងបង្ខាំងអាចសង់ឡើងពីសំភារៈដែលមានស្រាប់ ឬនៅក្នុងស្រុកដូចជា ឫស្សី ធាងត្នោត កូនឈើមូល តូចៗ និងបង្គោល (រូបភាព៦) ។ ទោះបីយ៉ាងណាក៏ដោយ បច្ចុប្បន្ននេះ សំណាញ់ជ័រដែលមានទំហំ ផ្សេងៗគ្នាមានលក់នៅទីផ្សារ ។

- ទ្រុងមាន់អាចសាងសង់នៅក្នុងទីតាំងដែលបានធ្វើរបងបង្ខាំង (រូបភាព៧) ដែលអាចសំរួលដល់ការ ចំណាយពេលក្នុងការបញ្ចូលមាន់ទៅក្នុងទ្រុងនៅពេលល្ងាច ។ ទីតាំងបាំងរបងមានដូចតទៅ ៖

  - របងមានកំពស់ ១,៨-២ម៉ ដើម្បីការពារមិនឱ្យមាន់ហើរចេញក្រៅ
  - លទ្ធភាពផ្សេងដើម្បីការពារមិនឱ្យមាន់ហើរចេញក្រៅនោះ គឺការកាត់រោមនៅតាមបណ្តោយស្លាប ចំនួន ៤-៥ នៅលើស្លាបទាំងសងខាងរបស់មាន់ ។
  - ក្នុងករណីធ្វើរបងទាបនោះ (១,៥ម៉) ត្រូវគ្រប់ផ្នែកខាងលើឱ្យជិតដោយប្រើសំភារៈដែលអាចឱ្យមានពន្លឺថ្ងៃចូលគ្រប់គ្រាន់ (រូបភាព ៨) ។

- សម្រាប់អ្នកភូមិដែលរស់នៅក្បែរឡូត៍នេសាទ អាចទិញព្រួលចាស់ ឬសំណាញ់ចាស់ៗ មកសាងសង់ទ្រុង និងរបងបាន ។



រូបភាព ៧ គំរូនៃការបង្ខាំងរបៀបនេះ ល្អប្រសើរណាស់ ដោយវាផ្តល់ទីធ្លាសម្រាប់មាន់ធ្វើចលនា ។



រូបភាព ៨ ទីធ្លាបានបិទជិតផ្នែកខាងលើ ជៀសវាង មិនឱ្យមាន់ហើរចេញក្រៅ ។




គំរូ ៤ បង្កើតលក្ខខណ្ឌចាំបាច់នៅក្នុងប្រព័ន្ធចិញ្ចឹមបង្ខាំង

- នៅក្នុងប្រព័ន្ធចិញ្ចឹមមាន់ដែលបានលើកឡើងនេះ មាន់ត្រូវបានចិញ្ចឹមដាក់ទ្រុងដែលស្ថិតនៅក្នុងទីតាំងមួយ ដែលមានបង្កលទ្ធភាពសម្រាប់មាន់ធ្វើចលនានៅក្នុងទីកន្លែងដែលមានរបងបាំង ។ ដើម្បីធ្វើដូច នេះបានតម្រូវឱ្យមានការគ្រប់គ្រងមួយល្អ និងចំណីអាហារគ្រប់គ្រាន់ (គំរូ ៤) ។ ហេតុដូចនេះ ហើយជាការចាំបាច់ ត្រូវផ្តល់ការណែនាំដល់កសិករបង្កើតឱ្យមានលក្ខខណ្ឌដូចខាង ក្រោមនេះ ៖

  - សាងសង់ទ្រុងមាន់នៅចំកណ្តាលទីតាំងព័ទ្ធរបង ។ ប្រសិនណាទ្រុងសង់នៅក្បែររបង ធ្វើមាន់អាច ឡើងទំលើដំបូល ដើម្បីហើរចេញក្រៅរបង ។
  - ព័ទ្ធរបងនៅទីតាំងដែលមានទំហំ ៦ម៉ គុណ ១០ម៉ ។
  - បង្កើតឱ្យមានម្លប់នៅក្នុងទីតាំងព័ទ្ធរបង ។ កសិករគួរដាំដើមឈើ និងដំណាំមួយចំនួនសម្រាប់ធ្វើជាម្លប់ ហើយរុក្ខជាតិដាំជាម្លប់នោះអាច បេះសម្រាប់ធ្វើជាចំណីសត្វបានដូចជា មរម្ស អង្គារដី ដំឡូងឈើ ល្ហុងប្រេង ។ល។
  - បង្កើតកន្លែងមួយនៅក្នុងទីតាំងព័ទ្ធរបង ដើម្បីទាក់ទាញសត្វល្អិតដូចជា ចង្រិត ក្រឡាតដី ដង្កូវ ។ល។ ដែលជាប្រភពប្រូតេអ៊ីនយ៉ាងល្អសម្រាប់មាន់ ។

### ៣.៤ ចំណី និងការផ្ដល់ចំណី

នៅក្នុង ‘TIP’ សម្រាប់កូនមាន់ ១-៤៥ថ្ងៃ មានតារាងជម្រើសនៃការលាយចំណី រួមបញ្ចូលទាំងបច្ចេកទេសងាយៗមួយចំនួន សម្រាប់ផលិតចំណីសត្វ ត្រូវបានរៀបចំឡើងសម្រាប់អ្នកផ្សព្វផ្សាយ និងកសិករដើម្បីជ្រើសរើសយោលទៅតាមលក្ខខណ្ឌ និងលទ្ធភាពរបស់ពួកគេ ។ នៅពេលនេះវិធីប្រហាក់ប្រហែលគ្នានេះ ត្រូវបានយកមកប្រើប្រាស់នៅក្នុង ‘TIP’ សម្រាប់មាន់បំប៉នដែលមានអាយុចាប់ពី ៤៥- ១៥០ថ្ងៃ តែចំណី នេះត្រូវបានរៀបចំយោលទៅតាមតម្រូវការប្រូតេអ៊ីន និងរ៉ែសម្រាប់មាន់ប្រភេទនេះ ។ ខាងក្រោមនេះជាការណែនាំមួយចំនួនសម្រាប់អនុវត្ត ‘TIP’ នេះ ៖

- នៅក្នុងការចិញ្ចឹមមាន់ជាលក្ខណៈបុរាណ មាន់ស៊ីចំណីសេសសល់ជ្រុះក្រោមផ្ទះ ឬគុ បន្លែសេសសល់ និងកាកសំណល់ ហើយជួនកាលមាន់ទាំងនោះត្រូវបានផ្តល់បន្ថែមគ្រាប់ធញ្ញជាតិដូចជា ស្រូវ ឬអង្ករ ដែលធ្វើឱ្យមាន់ទាំងនោះអាចផ្តល់មកវិញជាសាច់សម្រាប់ជាម្ហូបគ្រួសារ ។ កសិករខ្លះផលិតស្រូវបានច្រើនជាងតម្រូវការ ដូចនេះហើយស្រូវដែលលើសពីតម្រូវការហូបក្នុងគ្រួសារអាចលក់តែអាចចំណេញបានច្រើន ជាងនៅពេលផ្តល់ជាចំណីមាន់ ។
- នៅពេលដែលកសិករមានបំណងយកមាន់ជាមុខរបរមួយសម្រាប់ផ្តល់ចំណូលនោះ ពួកគាត់ត្រូវរកវិធី ផ្លាស់ប្តូរថ្មី ដែលអាចយល់ពីគោលគ្រឹះនៃតម្រូវការអាហាររូបត្ថម្ភរបស់មាន់ និងទីផ្សារ ។ ហេតុដូច្នេះហើយ ពួកគាត់ត្រូវមានផែនការ និងកំណត់ត្រានៃការចំណាយដើម្បីធ្វើឱ្យពួកគេអាចគណនា ប្រាក់ចំណេញ ។
- មាន់ក៏ដូចជាសត្វដទៃទៀតដែរ អាចត្រូវការចំណាយប្រមាណ ៧៥% ទៅលើចំណីនៃបរិមាណចំណាយសរុបចាប់ពីការផ្តើមចិញ្ចឹមរហូតដល់លក់ ។ ដូចនេះហើយជាការប្រសើរណាស់ដែលត្រូវប្រើផលិតផល និងអនុផលនៅកសិដ្ឋាន ដើម្បីកាត់បន្ថយទៅលើការចំណាយ ។
- សម្រាប់កសិករខ្នាតតូចដែលចិញ្ចឹមមាន់ ប្រមាណ២០០ក្បាល ក្នុងមួយឆ្នាំ ត្រូវកាត់បន្ថយការពឹងផ្អែក ឱ្យតិចបំផុតទៅលើធនធានខាងក្រៅ ដោយចាប់ផ្តើមផលិតចំណីនៅក្នុងកសិដ្ឋានរបស់ខ្លួន ។
- ករណីនេះហើយដែលចាំបាច់ឱ្យអ្នកផ្សព្វផ្សាយ និងអ្នកចិញ្ចឹមសត្វ ត្រូវធ្វើការជាមួយគ្នា ដើម្បីស្វែងរកធនធានចំណីក្នុងស្រុក និង ណែនាំឱ្យដាំដំណាំចំណីមួយចំនួនមានសក្តានុពលដែលអាចផលិតបានទាំងបរិមាណ និងគុណភាពសម្រាប់ជាចំណីមាន់ ។ ធនធានទាំងនោះបានលើកឡើងនៅក្នុង ‘TIP’ សម្រាប់កូន មាន់ ១-៤៥ថ្ងៃរួចហើយ ។
- ទោះបីជាប្រើធនធានដែលមាននៅក្នុងស្រុកក៏ដោយ ក៏ត្រូវធ្វើយ៉ាងណាឱ្យការឱ្យចំណីនៅតាមផ្ទះរបស់កសិករ បំពេញតាមតម្រូវការអាហាររូបត្ថម្ភរបស់មាន់ ។

### ២.៤.១ ចំណីលាយនៅផ្ទះកសិករ

នៅពេលដែលអ្នកផ្សព្វផ្សាយដាក់បញ្ចូលបច្ចេកទេសលាយចំណីនៅតាមផ្ទះកសិករនោះ ពួកគេត្រូវមានព័ត៌មានខ្លះទៅលើចំណីផ្សំដែលត្រូវយកទៅប្រើប្រាស់នោះ ដើម្បីមានលទ្ធភាពផ្តល់ការណែនាំដល់កសិករ ។ ព័ត៌មាន ស្តីពីធាតុផ្សំគីមីនៃចំណីផ្សំនោះមានសារៈប្រយោជន៍ណាស់ដោយសារអាចអនុញ្ញាតរៀបចំចំណីមានតុល្យភាពសារធាតុចិញ្ចឹមគ្រប់គ្រាន់ដូចជា ប្រូតេអ៊ីន និងថាមពល ជីវជាតិ និងរ៉ែសម្រាប់មាន់ ។

- ការរៀបចំចំណីមួយល្អ មិនសម្រាប់តែមាន់ចិញ្ចឹមជាលក្ខណៈឧស្សាហកម្មនោះទេ តែក៏ចាំបាច់សម្រាប់កសិករ ខ្នាតតូចដែលចិញ្ចឹមមាន់ស្រុកនោះដែរ ពីព្រោះចំណីនេះនឹងផ្តល់សារធាតុចិញ្ចឹមដែលមាន់ត្រូវការក្នុងការលូតឆាប់រហ័ស មានសុខភាពល្អ និងផលិតស៊ុតបានច្រើន ។
- ចំណីដែលមានតុល្យភាពសារធាតុចិញ្ចឹមនោះ អាចផលិតជាមួយធនធានចំណីក្នុងស្រុកឬផលិតក្នុង កសិដ្ឋានដោយប្រើប្រាស់ទុនតិចតួចពីខាងក្រៅ ។

ដើម្បីធ្វើទាំងអស់នោះបាន កសិករត្រូវសួរខ្លួនឯងថា:

- តើសារធាតុផ្សំចំណីអ្វីខ្លះដែលមាននៅក្នុងស្រុក/កសិដ្ឋានអ្នក មានបរិមាណប៉ុន្មាន ហើយមានតម្លៃ យ៉ាងដូចម្តេចដែរ?
- តើសារធាតុផ្សំចំណីទាំងនេះមានពេញមួយឆ្នាំ?
- តើសារធាតុផ្សំចំណីទាំងអស់នេះ អាចផលិតនៅក្នុងមូលដ្ឋាន/ស្រុក?
- តើអាចទៅរកសារធាតុផ្សំចំណីនៅឯណា ដែលមិនផលិតបាននៅក្នុងស្រុក/កសិដ្ឋាន?
- តើសារធាតុផ្សំចំណីទាំងអស់នោះអាចលាយបញ្ចូលគ្នាជាចំណីមួយ ឬមួយត្រូវទិញចំណីពីកន្លែងផ្សេងទៀត?
- នៅពេលដែលការចិញ្ចឹមមាន់ជាខ្នាតកណ្តាល កសិករត្រូវរកជំនួយពីអ្នកផ្សព្វផ្សាយ ឬអ្នកមានជំនាញចិញ្ចឹមសត្វដើម្បីជួយរៀបចំចំណីនេះ ។ ទោះយ៉ាងណាក៏ដោយការសាកល្បងចុងក្រោយទៅលើសារធាតុផ្សំចំណីស្ថិតនៅលើការលូតលាស់របស់មាន់ ។

គុណភាពរបស់សារធាតុផ្សំចំណីលាយសម្រាប់មាន់ អាចផ្លាស់ប្តូរទៅតាមកត្តាមួយចំនួន ប៉ុន្តែក្នុងចំណោម នោះមានបច្ចេកទេសនៃការទុកដាក់ និងពេលវេលា ។ ការកែឆ្នៃនានាក៏មានអំពើទៅលើគុណភាពចំណី ដែរ ។ ដូចបានលើកឡើងរួចហើយថា កសិករត្រូវពឹងផ្អែកទៅលើផលិតផលនៅក្នុងកសិដ្ឋានរបស់ខ្លួន ដោយសារគាត់មានលទ្ធភាពត្រួតពិនិត្យទៅលើគុណភាព និងត្រូវការតិចតួចពីទីផ្សារ ។

***សារធាតុផ្សំចំណីពីទីផ្សារ***

ទោះបីផ្តល់ការណែនាំដល់កសិករឱ្យប្រើសារធាតុផ្សំចំណីផលិតនៅក្នុងកសិដ្ឋាន ក៏មិនបានសេចក្តីថា គ្រប់ធនធានផ្សំចំណីនៅក្នុងស្រុកអាចយកមកលាយចំណី ហើយផ្តល់ចំណីដែលមានសារធាតុចិញ្ចឹម ជាពិសេស ប្រូតេអ៊ីនគ្រប់គ្រាន់តាមប្រភេទចំណី ដើម្បីបំពេញតាមសេចក្តីត្រូវការរបស់មាន់ ។ ដូចនេះហើយ ចំពោះ កសិករដែលមិនបានផលិតសារធាតុផ្សំចំណីនៅក្នុងកសិដ្ឋានរបស់ខ្លួនដែលមានគុណភាពល្អនោះ ពួក គាត់អាច ទិញពីផ្សារដែលនៅក្បែរនោះ ដូចជាៈ

- ម្សៅត្រី
- សណ្តែកសៀង
- ម្សៅសំបកខ្យង ឬឆ្អឹង
- អំបិល

តារាងទី ១ សារធាតុស្ងួត និងប្រូតេអ៊ីននៃសារធាតុផ្សំចំណីជ្រើសរើសមួយចំនួនពីទីផ្សារ

| ***សារធាតុផ្សំចំណី*** | ***សារធាតុស្ងួត*** (%) | ***ប្រូតេអ៊ីន*** (%) |
|---|---|---|
| ម្សៅត្រី | ៨៨ | ៣៥ |
| ត្រីស្រស់ | ២៥ | ៣៥ |
| សណ្តែកសៀង | ៨៩ | ៤៣ |

**ចំណាំ**

- ដើម្បីទទួលសារធាតុផ្សំចំណីបានតម្លៃថោក ជាចាំបាច់កសិករត្រូវទិញផលិតផលទាំងនោះនៅ រដូវប្រមូលផល ។

***សារធាតុផ្សំផលិតនៅកសិដ្ឋាន***

ដូចបានលើកឡើងនៅក្នុង ‘TIP’ នេះ សម្រាប់មាន់អាយុ ១-៤៥ថ្ងៃ មានដំណាំដែលមានសក្តានុពលជា ច្រើនដែលកសិករអាចផលិតនៅកសិដ្ឋានរបស់គេ ឬដែលមាននៅក្នុងភូមិ ។ ដូចនេះដើម្បីកាត់ការចំណាយ លើផលិតកម្ម កសិករត្រូវផលិត និងប្រើប្រាស់ផលិតផល និងអនុផលនៃកសិដ្ឋាន ដូចជាៈ

- ចុងអង្ករ និងកន្ទក់
- ត្រីល្អិតៗ និងកំពិស
- ត្រកួន
- ស្លឹកដំឡូងឈើ
- ស្លឹកមន
- ចកបាយទា
- ជន្លេន ។ល។

តារាងទី ២ ម៉ាស់ស្ងួត និងប្រូតេអ៊ីនសារធាតុគីមីនៃសមាសធាតុផ្សំចំណីដែលបានប្រើប្រាស់នៅក្នុងជម្រើសទាំង ៦ ខាងលើ

| **សមាសធាតុផ្សំចំណី** | **ម៉ាស់ស្ងួត** | **ប្រូតេអ៊ីន** |
|---|---|---|
| ចុងអង្ករ | ៨៨ | ៨ |
| កន្ទក់ | ៨៨ | ១១ |
| ត្រីស្រស់ | ២៥ | ៥០ |
| ជន្លេន | ២៥ | ៤០ |
| ចកបាយទា | ៥ | ៣៥ |
| ស្លឹកត្រកួន | ១២ | ៣០,៦ |
| ម្សៅស្លឹកមរម្យ | ៨៥ | ២៤ |
| ម្សៅស្លឹកមន | ៨៨ | ២៥ |
| ម្សៅស្លឹកដំឡូងឈើ | ៨៨ | ២២ |

*ទិន្នន័យវិភាគនៅមន្ទីរពិសោធន៍នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម "សៃលអាគ្រីត"

ខាងក្រោមនេះជាជម្រើសផ្សេងៗនៃការរៀបចំចំណីសម្រាប់មាន់កំពុងលូតលាស់ (តារាងទី ៣) និងមាន់ពង (តារាងទី ៤) ដែលអ្នកផ្សព្វផ្សាយអាចផ្តល់ការណែនាំដល់កសិករ ៖

**តារាងទី ៣ ជម្រើសនៃការលាយចំណី ១០ គីឡូក្រាម សម្រាប់មាន់កំពុងលូតលាស់8**

| **សមាសធាតុផ្សំចំណី** | **បរិមាណ គិតជាគីឡូក្រាម** | | | | | |
|---|---|---|---|---|---|---|
| | ជម្រើស ១ | | ជម្រើស ២ | | ជម្រើស ៣ | |
| | គក្រ | រង្វាល់ | គក្រ | រង្វាល់ | គក្រ | រង្វាល់ |
| ចុងអង្ករ | ៥ | ៣០ កំប៉ុង | ៥ | ៣០ កំប៉ុង | ៥ | ៣០ កំប៉ុង |
| កន្ទក់ | ១,៥ | ១២ កំប៉ុង | ១,៥ | ១២ កំប៉ុង | ១,៥ | ១២ កំប៉ុង |
| ម្សៅត្រី | | | ១ | ៥ កំប៉ុង | ០,៣ | ២ កំប៉ុង |
| សណ្តែកសៀង | ១ | ៥ កំប៉ុង | | | ០,៧ | ៣ កំប៉ុង |
| ម្សៅស្លឹកដំឡូងឈើ | ២,៥ | ៣១ លី្ | | | ២,៥ | ៣១ កំប៉ុង |
| ស្លឹកមន | | | ២,៥ | ៣១ កំប៉ុង | | |
| អំបិល | ០,០៤ | | ០,០៤ | | ០,០៤ | |
| ប្រូតេអ៊ីន % | ១៥,៥ | | ១៥,៤ | | ១៥,២ | |

**តារាងទី ៤ ជម្រើសនៃការលាយចំណី ១០ គីឡូក្រាម សម្រាប់មាន់ពង8**

| **សមាសធាតុផ្សំចំណី** | **បរិមាណ គិតជាគីឡូក្រាម** | | | | | |
|---|---|---|---|---|---|---|
| | ជម្រើស ១ | | ជម្រើស ២ | | ជម្រើស ៣ | |
| | គក្រ | រង្វាល់ | គក្រ | រង្វាល់ | គក្រ | រង្វាល់ |
| ចុងអង្ករ | ៤,២ | ២៥ កំប៉ុង | ៤,២ | ២៥ កំប៉ុង | ៤,២ | ២៥ កំប៉ុង |
| កន្ទក់ | ៣,៥ | ២៩ កំប៉ុង | ២,៣ | ១៩ កំប៉ុង | ២,៣ | ១៩ កំប៉ុង |
| ម្សៅត្រី | ១,២ | ៦ កំប៉ុង | ០,៧ | ៤ កំប៉ុង | | |
| សណ្តែកសៀង (គ្រាប់) | ០,៨ | ៣ កំប៉ុង | | | ០,៧ | ៣ កំប៉ុង |
| ម្សៅស្លឹកដំឡូងឈើ | | | ២,៥ | ៣១ កំប៉ុង | ២,៥ | ៣១ កំប៉ុង |
| អំបិល | ០,១ | | ០,១ | | ០,១ | |
| ម្សៅសំបកខ្យង | ០,0៤ | | ០,២ | | ០,២ | |
| ប្រូតេអ៊ីន % | ១៥ | | ១៥,៤ | | ១៤,៥ | |

*ផ្តល់ស្លឹកត្រកួនស្រស់ចំនួន ០,៤-០,៥ គីឡូក្រាម ឬចកបាយទាដែលបានហាលឱ្យស្ងួតទឹក សម្រាប់មាន់ ១០ ក្បាល នឹងបង្កើនបរិមាណប្រូតេអ៊ីន វីតាមីន និងប្រូតេអ៊ីន ។

**ទឹក**

សារៈប្រយោជន៍របស់ទឹកនៅក្នុងផលិតកម្មមាន់ មិនគួរឱ្យតម្លៃតិចតួចនោះទេ ។ ផលិតកម្មមាន់នឹងបរាជ័យប្រសិនណាមិនផ្តល់ទឹកឱ្យគ្រប់គ្រាន់តាមតម្រូវការរបស់មាន់ ជាពិសេសនៅរដូវក្តៅ (រដូវប្រាំង-ជាពិសេសខែមិនា និងមេសា) ។ ការផ្តល់ទឹកឱ្យបានគ្រប់គ្រាន់សម្រាប់មាន់នោះ ជាការប្រសើរណាស់ សម្រាប់ការ លូតលាស់ល្អ និងពងបានច្រើន ។ ខាងក្រោមនេះជាការប៉ាន់ស្មាននៃការស៊ីចំណី និងទឹក (តារាងទី ៥) ៖

**តារាងទី ៥ ការប៉ាន់ប្រមាណទៅលើការស៊ីចំណី និងផឹកទឹកនៃមាន់ពូជក្នុងស្រុក ចិញ្ចឹមជាក់ស្តែង**

| **អាយុ (សប្តាហ៍)** | **ការស៊ីចំណី (គ.ឡ សម្រាប់មាន់ ១០ក្បាល ក្នុង ១ថ្ងៃ)** | **ការផឹកទឹក (សម្រាប់មាន់ ១០ ក្បាលក្នុងមួយថ្ងៃ (លិត្រ)** |
|---|---|---|
| ១-៥ | ០,១៥-០,៣ | ០,២-១ |
| ៦-១០ | ០,៤-០,៦ | ១,១-១,៩ |
| ១១-១៦ | ០,៧-០,៧៥ | ២,៣-២,៥ |
| ១៧-២១ | ០,៨ | ២,៧ |
| ២២-២៤ | ០,៨-១ | ២,៨-៣ |

*តួលេខនៃបរិមាណចំណីស៊ីនេះ ត្រូវបានផលិតឡើងតាមការពិសោធន៍ទៅលើមាន់ដែលបានឱ្យស៊ីចំណីមាន ម្សៅត្រី ម្សៅស្លឹកដំឡូងឈើ ចុងអង្ករ កន្ទក់ អំបិល និងព្រីមិចក្នុងរយៈពេល ៤ខែ (ខែមេសា-កក្កដា ឆ្នាំ ២០០៥) នៅសែលអាគ្រិត ។

## ខ្យាច់

មាន់គ្មានធ្មេញដើម្បីជួយបំបែកអាហារនោះទេ ដូច្នេះហើយបានជាមាន់ចឹកខ្សាច់ គ្រួសតូចៗ ។ នៅពេលខ្សាច់ និងគ្រួសតូចៗចូលទៅក្នុងកោះ អាចជួយកិនកំទិចគ្រាប់ធញ្ញជាតិ និងចំណីរឹងផ្សេងៗទៀត មុននឹងឆ្លងចូលទៅក្នុងពោះវៀនតូច ។ គ្រាប់គ្រួសតូចៗ និងខ្សាច់អាចជួយយ៉ាងច្រើន នៅពេលដែលចំណី មានជាតិ សសៃច្រើន ឬចំណីរឹងដូចជា ម្សៅស្លឹកដំឡូងឈើ ម្សៅស្លឹកមន ស្លឹកត្រកួនចិញ្ច្រាំតូចៗ ។ល។ ដូច្នេះ សម្រាប់មាន់ចិញ្ចឹមនៅក្នុងទ្រុង គួរមានកំប៉ុងជ័រដែលមានខ្សាច់តូចៗនៅក្នុងនោះ ហើយដាច់ក្បែរស្នូក ចំណី សម្រាប់ឱ្យមាន់ចឹកស៊ី ប្រសិនបើវាចង់ ។ ប៉ុន្តែខ្សាច់តូច មិនចាំបាច់ឱ្យមានទេ នៅពេលមាន់ចិញ្ចឹមនៅ ក្នុង របងដែលអាចឱ្យមាន់រើសខ្សាច់តូចស៊ីបាន ។

## ការទុកដាក់ចំណី

ដើម្បីរក្សាទុកចំណីមិនឱ្យមានការខូចរលួយ ដោយសារសំណើម កណ្តុរ សត្វល្អិត ។ល។ ត្រូវអនុវត្តតាមចំណុចដូចខាងក្រោមនេះ

- រក្សាចំណីទុកក្នុងថង់ ការុង និងបាវដែលចងមាត់ជិត
- រក្សាទុកក្នុងពាង ឡាំងឈើ ឬក្នុងទីកន្លែងមួយបិទជិតមិនឱ្យសត្វចូលបាន
- រក្សាទុកចំណីឱ្យផុតពីទីកន្លែងសើម និងទឹកភ្លៀង ។ គ្របប្លាស្ទិកឱ្យជិតដើម្បីជៀសវាងភ្លៀងសាច ។
- ចងមាត់ចង់ក្រោមពីចំណីឱ្យមាន់ស៊ីរួច ។

## ចំណាំ

- លាយចំណីសម្រាប់រយៈពេលតែ ៤សប្តាហ៍ប៉ុណ្ណោះ
- វត្ថុធាតុដើមប្រើក្នុងការលាយចំណី ត្រូវឱ្យស្ងួត
- ក្នុងករណីប្រើចកបាយទា និងត្រកួន ត្រូវប្រើស្រស់ ។

## ស្នូកចំណី និងទឹក

មានប្រភេទស្នូកទឹក និងចំណីជាច្រើនដែលអាចប្រើប្រាស់បាន ។ គោលបំណងសំខាន់ ត្រូវធ្វើយ៉ាងណាឱ្យវារឹងមាំ និងធ្វើឱ្យមានការបាត់បង់ចំណីតិចតួច ។

- *ស្នូកចំណី*

អាចប្រើស្នូកប្លាស្ទិកដែលមានលក់នៅតាមទីផ្សារ (រូបទី ៩) និងភាគច្រើនត្រូវបានប្រើសម្រាប់ ការចិញ្ចឹមមាន់ជាលក្ខណៈឧស្សាហកម្ម ប៉ុន្តែក៏អាចប្រើសម្រាប់ការចិញ្ចឹមជាលក្ខណៈកសិករបានដែរ នៅ ពេលដែលវាមានតម្លៃថោកសមរម្យ ។ ស្នូកប្រភេទនេះ ត្រូវដាក់ប្រមាណ ១២សម ពីដីដោយប្រើ ខ្សែលួសចងភ្ជួរ ។ ទោះបីយ៉ាងណាក៏ដោយ ក៏សំណូមពរឱ្យកសិករប្រើសំភារះដែលមាននៅក្នុងស្រុក ដើម្បីកាត់បន្ថយការចំណាយ ។



រូបភាពទី ៩ ស្នូកចំណីប្លាស្ទិក



រូបភាពទី ១០ ស្នូកទឹកប្លាស្ទិក

ស្នូកចំណី ក៏អាចធ្វើបានដោយប្រើឫស្សីដែរ ។ កសិករត្រូវជ្រើសរើសឫស្សីដែលមានអង្កត់ផ្ចិតទំហំ ៥-៧សម និងប្រវែង ២៥-៣០សម ។ ស្នូកចំណីឫស្សីត្រូវមានជើងទប់ឱ្យហ្នឹង ២-៣ (គំនូរទី ៥) ។ ជាការចំបាច់ ណាស់ដែលត្រូវចែកស្នូកជាប្រលោះតូចៗនៅផ្នែកខាងលើដោយប្រើលួស ធ្វើដូចនេះ អាចកាត់បន្ថយការខ្ជាយ ចំណី ។



គំនូរទី ៥ ស្នូកទឹកធ្វើពីឬស្សី

- *ស្នូកទឹក*

ស្នូកប្លាស្ទិក (រូបទី ១០) ប្រើសម្រាប់ការចិញ្ចឹមមាន់ជាលក្ខណៈឧស្សាហកម្ម បច្ចុប្បន្ននេះមានលក់នៅ តាមទីផ្សារនៅតាមបណ្ដាខេត្ត ។ សម្រាប់គ្រួសារកសិករដែលចិញ្ចឹមមាន់ប្រមាណ ៥០ក្បាលក្នុងមួយវដ្ដ ផលិតកម្ម កសិករអាចទិញស្នូកនៅតាមទីផ្សារ ចំនួន ៣-៤ អាចគ្រប់គ្រាន់ ហើយប្រើប្រាស់បាន ២-៣ឆ្នាំ ប្រសិនបើមាន ការថែទាំបានល្អ ។ ទន្ទឹមនេះកសិករ ក៏អាចធ្វើស្នូកទឹកដោយប្រើកំប៉ុងដែក (កំប៉ុងទឹកដោះគោ ម្សៅក្មេង) និង ថាសជ័រ ឬដែក (គំនូរទី ៦) ។ ត្រូវចោះរន្ធតូចៗជុំវិញកំប៉ុងទឹកដោះគោ ដែលមានកំរិត ៣ភាគ៤ ពីបាតថាស ទម្រជ័រ ឬប្លាស្ទិក ធ្វើតាមវិធីនេះ នៅសល់ ១ភាគ៤ ដែលអាចផ្ដល់សំពាធមិនឱ្យទឹកហូរ ចេញក្រៅ ។



គំនូរទី ៦ ស្នូកទឹកធ្វើពីកំប៉ុងទឹកដោះគោ (កំប៉ុងម្សៅទឹកដោះគោម្សៅសម្រាប់ក្មេង)

## ២.៥ ជម្ងឺ និងការការពារ

មាន់ជារបរមួយល្អសម្រាប់កសិករនៅជនបទ ដើម្បីធ្វើឱ្យប្រសើរដល់ជីវភាពរស់នៅរបស់ពួកគេ និងតម្រូវវិនិយោគទាបជាងសត្វដទៃដើម្បីចាប់ផ្តើម ។ ផ្ទុយទៅវិញការចិញ្ចឹមមាន់ តម្រូវឱ្យមានការថែទាំជិត ដល់ប្រៀបជាមួយសត្វដទៃដែរ ។ ខាងក្រោមជាវិធានការណ៍ល្អៗនានាដែលត្រូវណែនាំឱ្យកសិករទាញយក ផលប្រយោជន៍សម្រាប់ការចិញ្ចឹមមាន់របស់គេ ៖

- មិនត្រូវទិញ ឬក៏យកមាន់ចូលពីកន្លែងដទៃដូចជា ទីផ្សារ ចូលទៅក្នុងកសិដ្ឋានខ្លួន ។
- ឱ្យមាន់ស៊ីចំណីដែលមានគុណភាពល្អ ដើម្បីជៀសវាងការកើតជម្ងឺដោយសារការគ្មានអាហាររូបត្ថម្ភ ។
- ផ្តល់ចំណីបៃតង ដូចជា ត្រកួន មន ចកបាយទា ។ល។ ដែលដាំនៅក្នុងកសិដ្ឋានរបស់ខ្លួន ។ ចំណីទាំងនេះនឹងផ្តល់ ប្រូតេអ៊ីន ជីវជាតិ និងរ៉ែបន្ថែមដល់មាន់ ។
- មិនចិញ្ចឹមមាន់លាយជាសត្វស្លាបដទៃទៀត ដូចជា ទា ក្ងាន មាន់បារាំង ។
- មិនទិញមាន់ពេញវ័យ ឬជិទង់ដើម្បីដាក់បញ្ចូលបន្ថែមទៅក្នុងហ្វូងមាន់ចិញ្ចឹមរបស់អ្នក ពីព្រោះវាអាចនាំមកនូវជម្ងឺដល់មាន់អ្នក ។ ត្រូវចិញ្ចឹមកូនមាន់ផ្សេងពី មាន់ធំ ។
- ធ្វើទ្រុងមាន់ឱ្យមានខ្យល់ចេញចូលល្អ និងម្លប់ដើម្បីឱ្យមាន់អាចជ្រកនៅរដូវក្តៅខ្លាំង ។

- សំអាតកន្លែងរស់នៅរបស់មាន់ឱ្យមានអនាម័យល្អ និងស្ងួត ។ ដើម្បីងាយស្រួលប្រមូលលាមក ត្រូវក្រាលអង្កាម តែត្រូវពង្រាបអង្កាមកំរាល ១-២ដង ក្នុងមួយសប្តាហ៍ ហើយប្រសិនបើមិនសើមទេនោះ អាចប្តូរថ្មី ក្នុងរយៈពេល ២សប្តាហ៍ម្តង ។
- ដាក់ទឹកស្អាត ហើយថ្មីនៅទីតាំងដែលមាន់ងាយស្រួលផឹក ។ ត្រូវលាងស្នូកទឹក និងចំណីជាប្រចាំ ។
- យកមាន់ឈឺចេញក្រៅទ្រុង ។ កប់មាន់ងាប់ឱ្យបានជ្រៅ ។ កសិករមិនគួរលក់មាន់ងាប់ទេ ។
- មិនឱ្យឆ្កែ ឆ្មារ មកនៅក្បែរទ្រុងមាន់ ហើយធ្វើយ៉ាងណាមិនឱ្យមានរន្ធកណ្តុរនៅទីនោះ ។
- ទ្រនុំមាន់ធ្វើយ៉ាងឱ្យលាមកងាយស្រួលធ្លាក់មកក្រោម ហើយងាយស្រួលប្រមូល ។
- នៅពេលប្រើទ្រុងមួយដាក់មាន់សាច់ និងមាន់ពងត្រូវប្រយ័ត្នធ្វើយ៉ាងណាការពារមិនឱ្យមាន់ដេកលើសំបុកពង ព្រោះជុះអាចម៍លើ ធ្វើឱ្យស៊ុតខូចគុណភាព ។
- អនុវត្តតាមការណែនាំការចាក់ថ្នាំបង្ការ ។

ក្នុងករណីផ្ទុះជម្ងឺឡើង កសិករត្រូវទាក់ទងជាមួយអ្នកផ្សព្វផ្សាយ និងពេទ្យសត្វភូមិភ្លាម ដើម្បីទទួលការណែនាំ និងធ្វើការវិភាគរោគសញ្ញា ។

## ២.៥.១ ជម្ងឺសំខាន់ៗលើមាន់នៅកម្ពុជា

***ញ្ញូវកាសល (ដង្កោរ)***

ជម្ងឺនេះមានការឆ្លងយ៉ាងខ្លាំង បង្កឡើងដោយវីរុស ដែលចំលងពីមាន់មួយទៅមួយទៀតយ៉ាងឆាប់រហ័ស ។ រោគសញ្ញាដែលកើតឡើងនៅលើមាន់មាន ដកដង្ហើមខ្លីៗ ក្អក និងស្អក ។ ការមិនឃ្លានចំណី និងសំកុកជាសញ្ញាបង្ហាញសំខាន់ផងដែរ ។ ចំពោះមាន់ពងជម្ងឺនេះ កើតម្តងស្ទើរតែគ្រប់មាន់ទាំងអស់ ។ រោគសញ្ញាសំគាល់សំខាន់នោះ គឺមាន់មួយចំនួនបត់ករចុះក្រោម ។ ផលិតកម្មពងធ្លាក់ចុះស្ទើរតែគ្មានពង ហើយសំបកពងខ្លះទន់ ។ វិធីល្អសម្រាប់ជម្ងឺនេះ គឺការចាក់ថ្នាំការពារ ។

***អាសន្នរោគមាន់***

ជម្ងឺនេះ ក៏ទទួលស្គាល់ផងដែរថា ជាជម្ងឺសារទឹក ។ ជម្ងឺនេះឆ្លងតាមលាមករបស់មាន់ឈឺ ។ ក្នុងករណីធ្ងន់ធ្ងរមួយចំនួន មាន់ងាប់ក្នុង ២៤ម៉ោង ។ មាន់អាចជាធម្មតាវិញមួយថ្ងៃក្រោយ ប៉ុន្តែអាចឃើញ ងាប់នៅមួយថ្ងៃក្រោយ ។ មាន់ចុះខ្សោយ សំកុកបិទភ្នែក និងករួញ ។ នៅពេលវះ ឃើញមានស្នាមឈាម អុចៗនៅបេះដូង និងសួត ។ យកល្អជម្ងឺនេះ គួរត្រូវបានការពារដោយការចាក់ថ្នាំបង្ការ ។

***អុតមាន់***

អុតមានការចំលងយឺតៗ បង្កឡើងដោយវីរុស អាចសំគាល់រោគសញ្ញានៅអុចលើស្បែកដែលគ្មាន រោម និងនៅតាមសងខាងចំពុះ និងរន្ធច្រមុះ ។ ជម្ងឺនេះមានកើតនៅលើមាន់គ្រប់អាយុ ជាពិសេសនៅក្នុងខែ ដែល

មានសីតុណ្ហភាពក្តៅ ហើយអាចចំលងដោយការប៉ះពាល់គ្នាផ្ទាល់ ឬតាមរយៈមូស ។ មាន់ឈឺមានការ លូតលាស់យឺត និងផលិតស៊ុតធ្លាក់ចុះ ។ គ្មានថ្នាំព្យាបាលជម្ងឺអុតទេ ប៉ុន្តែអាចចាក់ថ្នាំការពារបាន ដល់មាន់ ទាំងអស់ពីអាយុ ១២-១៦សប្តាហ៍ ដោយចាក់នៅលើស្លាប ។ បើមានមាន់ទទួលប្រតិកម្មច្រើន (ហើមស្បែក នៅលើស្លាប ឬកន្លែងចាក់វ៉ាក់សាំង) បង្ហាញថាទទួលបានជោគជ័យលើការចាក់ថ្នាំបង្ការនេះ ។

### ផ្តាសាយបក្សី

ផ្តាសាយបក្សីបង្កឡើយដោយ វីរុស H5N1 ត្រូវបានរាយការណ៍ថាមានកើតនៅកម្ពុជា នៅខេត្ត កំពតជាប់ព្រំប្រទល់ជាមួយប្រទេសវៀតណាម ។ រោគសញ្ញាមាន ការមិនឃ្លានចំណី រោមស្រអាប់ ក្តៅ ខ្សោយ រាគ ផឹកទឹកច្រើន និងហើម ។ បច្ចុប្បន្ន នៅពុំទាន់មានថ្នាំបង្ការជម្ងឺនេះ នៅប្រទេសកម្ពុជាទេ ។ ដើម្បីការពារការទាក់ទងគ្នារវាងមាន់ចិញ្ចឹម និងសត្វស្លាបព្រៃ ប្រព័ន្ធជីវសន្តិសុខត្រូវបានរៀបចំឡើយ (រូបទី ១១ និង១២) ។


រូបភាពទី ១១ ជីវសន្តិសុខសម្រាប់មាន់យកពង


រូបភាពទី ១២ ជីវសន្តិសុខសម្រាប់កូនមាន់

### ព្រូន

ព្រូនដែលកើតមាននៅលើមាន់ ធ្វើឱ្យការលូតលាស់មិនល្អ និងផលិតកម្មស៊ុតទាប ។ ការបង្ការ ដោយអនុវត្តអនាម័យល្អ ជាការងារមួយល្អសម្រាប់ទប់ស្កាត់ព្រូនគ្រប់ប្រភេទ ។ ព្រូនមិនជាបញ្ហាទេ នៅ ពេលដែលចិញ្ចឹមមាន់ក្នុងទ្រុង ។ ប្រសិនបើមាន់មានព្រូននៅក្នុងប្រព័ន្ធរំលាយអាហារ ត្រូវបញ្ចុះព្រូនជាបន្ទាន់ និងរៀងរាល់ ៣០ថ្ងៃបន្តបន្ទាប់ ។

ថ្នាំប៉េពីរ៉ាស៊ីន ជាថ្នាំសម្រាប់ទំលាក់ព្រូននេះ ប្រើនៅលើសត្វ និងមនុស្សផងដែរ ។ ដោយសារអ្នក ផលិតបញ្ចូលកំរិតថ្នាំនេះផ្សេងៗគ្នា អ្នកប្រើត្រូវមើលកំរិតអនុញ្ញាតប្រើប្រាស់ដោយអ្នកផលិត ។ មិនត្រូវ ឱ្យទឹកដល់មាន់ ៣ម៉ោង មុនពេលពេលឱ្យថ្នាំ ។ កំរិតថ្នាំត្រូវផ្តល់ឱ្យមាន់ ត្រូវលាយជាមួយទឹកសម្រាប់ ១,៥-២ម៉ោង ។ ឱ្យទឹកមាន់ផឹកភ្លាមក្រោយពេលដែលមាន់ផឹកទឹកលាយថ្នាំអស់ ។

***ការកត់ត្រា***

សៀវភៅកត់ត្រាមួយដូចបានលើកឡើងខាងក្រោម ត្រូវបានបង្កើតឡើងដើម្បីធ្វើការថ្ងៃ ខែ ឆ្នាំ ចំណាយ ទឹកប្រាក់ដែលបានចំណាយតាមកាលបរិច្ឆេទ និងប្រាក់ទទួលបានមកវិញតាមរយៈការលក់ពងមាន់ កំណើនទំងន់ក្នុងមួយសប្តាហ៍ម្តង ដើម្បីត្រួតពិនិត្យទៅលើការចិញ្ចឹមមាន់របស់អ្នក ។ ការកត់ត្រានេះ នឹង ជួយកសិករឱ្យកត់ត្រាលើជំនួញចិញ្ចឹមមាន់របស់គាត់ ។ ជាការចាំបាច់ណាស់ ត្រូវធ្វើការកត់ត្រាការចំណាយ និងចំណូលជាក់ស្តែងពីការលក់ពងមាន់ និងសាច់មាន់ ។ គ្មានការកត់ត្រា កសិករគ្មានមធ្យោបាយណាមួយ សម្រាប់ត្រួតពិនិត្យលើដំណើរការផលិតកម្ម ឬការចំណាយ និងការផ្លាស់ប្តូរផលចំណេញ ។

**ចំណាយលើមធ្យោបាយផលិតកម្ម**

ចំណាយពេលចាប់ផ្តើម

| មុខទំនិញ | ថ្ងៃ ខែ ឆ្នាំ | តម្លៃឯកតា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|
| សរសរ | ០១ ឧសភា ២០០៥ | ៥០០០ | ៥០០០០ | |
| ស្លឹកប្រក់ | ០១ ឧសភា ២០០៥ | ២០០ | ២០០០០ | ធ្វើខ្លួនឯង |
| ឫស្សី | ០១ ឧសភា ២០០៥ | ៨០០០ | ៨០០០០ | |
| ------ | | | | |
| ------ | | | | |
| ------ | | | | |
| ស្នូកទឹក-ចំណី | ០៥ ឧសភា ២០០៥ | ៤០០០ | ៨០០០ | |
| សំណាញ់ជ័រ | ០៥ ឧសភា ២០០៥ | ៦០០ | ៦០០០០ | |
| កូនមាន់ | ០៥ ឧសភា ២០០៥ | ២៥០០ | ១២៥០០០ | កូនមាន់ផ្ទាល់ខ្លួន |
| | | | | |
| | | | | |
| | | | | |
| | | | | |

ចំណាយប្រចាំសប្តាហ៍

គោលបំណងនៃផលិតកម្ម: ................ បំប៉នមាន់សាច់.............

ថ្ងៃខែឆ្នាំចាប់ផ្តើម: ... ០៣ ខែឧសភា ឆ្នាំ២០០៥ ចំនួនមាន់: ... ៥០ ...

ថ្ងៃ ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៥ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៥

| មុខទំនិញ | ថ្ងៃ ខែ ឆ្នាំ | តម្លៃឯកតា | តម្លៃសរុប | ផ្សេងៗ |
|---|---|---|---|---|
| ចំណី | | | | |
| ចុងអង្ករ | ១០ ឧសភា ២០០៥ | ៨០០ | ៤០០០ | ផលិតក្នុងកសិដ្ឋាន |
| កន្ទក់ | ១០ ឧសភា ២០០៥ | ៤០០ | ១២០០ | ផលិតក្នុងកសិដ្ឋាន |
| ម្សៅត្រី | ១០ ឧសភា ២០០៥ | ១៧០០ | ១៧០០ | |
| អំបិល | ១០ ឧសភា ២០០៥ | ៣០០ | ៣០០ | |
| ------ | | | | |
| ------ | | | | |
| ថ្នាំបង្ការ និងព្យាបាល | | | | |
| ញូកាស | ១៥ ឧសភា ២០០៥ | ១៥០ | ៧៥០០ | |
| ----- | | | | |
| ----- | | | | |
| ----- | | | | |
| | | សរុប | | |

## ២,៦ ផលប្រយោជន៍សេដ្ឋកិច្ច

ការសន្មត់នានា ប្រើសម្រាប់ការគណនាផលប្រយោជន៍សេដ្ឋកិច្ច មានដូចខាងក្រោមៈ

- ការចិញ្ចឹមមានជាលក្ខណៈបុរាណដោយលែងមាន់ឱ្យដើររកស៊ីមាន់ត្រូវបានផ្តល់ស្រូវឱ្យស៊ីបន្ថែម ឬ អង្ករ ។ សន្មត់ថាកសិករឱ្យស្រូវ ឬអង្ករមួយកំប៉ុង (ប្រមាណ ២៥០ក្រាម) ដល់មាន់ ១០-១៥ក្បាល (ប្រមាណ ១៥ ក្រាមក្នុងមាន់មួយក្បាលក្នុងមួយថ្ងៃ) ។
- ការវិភាគសេដ្ឋកិច្ចនេះ ធ្វើឡើងចំពោះតែការកែលំអទៅលើការផ្តល់ចំណី និងគ្រប់គ្រង ។ ហេតុដូចនេះហើយ បញ្ហាពាក់ព័ន្ធទៅលើសុខភាព ជាកត្តាមួយទៀតបន្ថែមទៀត ដោយសន្មត់ថាមានចិញ្ចឹមនៅប្រព័ន្ធទាំងពីរត្រូវបានចាក់ថ្នាំការពារជម្ងឺសំខាន់ៗ ។
- អាត្រាមាន់ងាប់ (ដោយសារសត្វចាប់ស៊ី) មាន ៥% សម្រាប់មាន់ចិញ្ចឹមតាមលក្ខណៈបច្ចេកទេស និង ៣០% សម្រាប់មាន់ចិញ្ចឹមតាមលក្ខណៈកសិករ ។

- តាមបទពិសោធន៍នៅសៃលអាគ្រីត មានពូជក្នុងស្រុកឱ្យចំណីមានស្លឹកដំឡូង ៣០% (ប្រហាក់ប្រហែល ចំណី ១) មានកំណើនទំងន់ ១៥ក្រាមក្នុងមួយថ្ងៃ ហើយមានចិញ្ចឹមតាមលក្ខណៈកសិករ ត្រូវការពេលវេលា ប្រមាណ ៥-៦ខែ ដើម្បីអាចមានទំងន់គ្រប់គ្រាន់សម្រាប់លក់ទៅទីផ្សារ ។
- អនុវត្តតាម បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ កសិករអាចចិញ្ចឹមមាន់ ៣-៤វដ្តដែលមានមាន់ចំនួន ៥០-៧០ មាន់ក្នុងមួយវដ្ត ។
- ជម្រើសចំណី ១ (មើលការសង្ខេបខាងលើ) ត្រូវបានយកមកប្រើប្រាស់សម្រាប់ការវិភាគសេដ្ឋកិច្ច ។ អ្នកផ្សព្វផ្សាយអាចប្រើតារាងសេដ្ឋកិច្ចខាងក្រោម ដើម្បីគណនាផលប្រយោជន៍សេដ្ឋកិច្ចនៃការប្រើប្រាស់ ចំណីដទៃទៀត អាស្រ័យទៅតាមភាពសមស្របនៃតំបន់នីមួយៗ ។ ទោះបីយ៉ាងណា ក៏វត្ថុធាតុដើម ដែលបាននៅក្នុងជម្រើសចំណីទាំង៦ប្រភេទ ជាទូទៅមាននៅស្ទើរតែគ្រប់តំបន់ទាំងអស់នៅប្រទេស កម្ពុជា ។

**ឧទាហរណ៍ ប្រៀបធៀបសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់លក្ខណៈកសិករ និងការកែលំអលើការផ្តល់ចំណី និងគ្រប់គ្រងមេមាន់សាច់ និងមានពងពូជក្នុងស្រុកសម្រាប់មួយគ្រួសារក្នុងមួយឆ្នាំ**

| | ទំលាប់កសិករ | | | កែលំអ | | |
|---|---|---|---|---|---|---|
| ប្រាក់ចំណូល | ទិន្នផល<br>៥ក្ប/ឆ្នាំ | តម្លៃ<br>រៀល/ឯកតា | ចំណូល<br>៥ក្ប/ឆ្នាំ | ទិន្នផល<br>៥ក្ប/ឆ្នាំ | តម្លៃ<br>រៀល/ឯកតា | ចំណូល<br>៥ក្ប/ឆ្នាំ |
| មាន់ | ១៤០គក្រ | ៨៥០០ | ១១៩០០០០ | ២៨៥គក្រ | ៨៥០០ | ២៤២២៥០០ |
| | | សរុប | ១១៩០០០០ | | | ២៤២២៥០០ |
| ការចំណាយ | បរិមាណ<br>មាន់/ឆ្នាំ | តម្លៃ<br>រៀល/ឯកតា | ចំណាយ<br>៥ក្ប/ឆ្នាំ | បរិមាណ<br>មាន់/ឆ្នាំ | តម្លៃ<br>រៀល/ឯកតា | ចំណាយ<br>៥ក្ប/ឆ្នាំ |
| កូនមាន់ | ២០០ | ២៥០០ | ៥០០០០០ | ២០០ | ២៥០០ | ៥០០០០០ |
| **ការប្រើប្រាស់ចំណីជម្រើសទី ១** | | | | | | |
| ស្រូវ | ៥៤០ | ៥៥០ | ២៩៧០០០ | | | |
| ចុងអង្ករ | | | | ៧៩៧ | ៨០០ | ៦៣៧៤៥០ |
| កន្ទក់ | | | | ២៣៩ | ៥៥០ | ១៣១៤៧៤ |
| សណ្តែកសៀង | | | | ១៥៩ | ២០០០ | ៣១៨៧២៥ |
| ម្សៅស្លឹកដំឡូងឈើ | | | | ៣៩៨ | ៥០០ | ១៩៩២០៣ |
| អំបិល | | | | ៦ | ៤០០ | ២៥៥០ |
| វ៉ាក់សាំង | | | | | | |
| ដង្កោរ | ២០០ | ១០០ | ២០០០០ | ២០០ | ១០០ | ២០០០០ |
| អាសន្នរោគមាន់ | ២០០ | ១០០ | ២០០០០ | ២០០ | ១០០ | ២០០០០ |
| អុតមាន់ | ២០០ | ១០០ | ២០០០០ | ២០០ | ១០០ | ២០០០០ |
| ទ្រុង (តម្លៃរំលោះ ៣០%) | | ១២០០០០ | ៤០០០០ | | ៤៨០០០០ | ១៥៨៤០០ |
| | | ចំណាយប្រាក់សរុប | ៨៩៧០០០ | | | ១៨៤៩៤០០ |
| | | ចំណេញសាច់ប្រាក់ | ២៩៣០០០ | | | ៥៧៣១០០ |
| **ចំណាយមិនមែនសាច់ប្រាក់ ............** | | | | | | |
| ពលកម្ម | ៤៦ | ៤០០០ | ១៨៤០០ | ៤៥ | ៤០០០ | ១៨០០០០ |
| | | **ចំណាយសរុប** | ១០៨១០០០ | | | ២០២៩៤០០ |
| | | **ប្រាក់ចំណេញ** | ១០៩០០០ | | | ៣៩៣១០០ |
| | | **ប្រាក់ទទួលបានគិតជាពលកម្មក្នុងមួយថ្ងៃ** | ៦៣៧០ | | | ១២៧៣៥ |
| | | | | | **ប្រាក់ចំណេញសុទ្ធពី មេមាន់ ៥ ក្បាល** | ២៨៤១០០ |
| | | | | | **បង្កើនចំណូលគ្រួសារតាមរយៈ មេមាន់ ៥ ក្បាល** | ២៨០១០០ |

## ២.៧ ផលប៉ះពាល់លើបរិស្ថាន

ដោយសារបច្ចេកវិទ្យាដែលបានលើកនៅក្នុង ”TIP” នេះ ត្រូវបានគ្រប់គ្រងតាមលក្ខណៈធម្មជាតិ ដោយ ប្រើប្រាស់ផល និងអនុផលកសិកម្ម ឬអ្វីដែលគាត់ផលិត ហេតុដូច្នេះហើយ ធ្វើឱ្យមានផលប៉ះពាល់ វិជ្ជមាន មួយចំនួនសម្រាប់បរិស្ថាន ។

មាន់ចិញ្ចឹមក្នុងទ្រុង មិនត្រឹមតែការពារទល់នឹងគ្រោះថ្នាក់មួយចំនួនប៉ុណ្ណោះទេ ប៉ុន្តែអាចការពារមាន់មិនឱ្យធ្វើការប៉ះពាល់ដល់ផលប្រយោជន៍កសិករផ្សេងទៀត ដូចជាការកកាយសួនបន្លែ ។

អនុវត្តតាម បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ អាចប្រមូលលាមកមាន់ ដែលអាចយកទៅប្រើប្រាស់ នៅលើដំណាំ និងជាពិសេសបន្លែដែលកាត់បន្ថយការប្រើប្រាស់ជីគីមី ។

---

## ៣-ការណែនាំលើការងារផ្សព្វផ្សាយ

### ៣.១ វិធីសាស្ត្រនៃការផ្សព្វផ្សាយ

វិធីផ្សព្វផ្សាយសម្រាប់ ’TIP’ នេះប្រហាក់ប្រហែលគ្នានឹង ’TIP’ កូនមាន់ ១-៤៥ថ្ងៃដែរ ហើយក៏អាចជាការបន្តពី ’TIP’ កូនមាន់ក៏បានដែរ ។ រៀបចំការងារផ្សព្វផ្សាយតាមវិធីនេះ អាចធានាភាពជោគជ័យ ហើយធានាឱ្យមានការទទួលយកបច្ចេកវិទ្យានេះទៅប្រើប្រាស់ ។

ដោយកសិករធ្វើការជាដៃគូរដូចបានរៀបរាប់នៅក្នុង ’TIP’ មុន ដូចច្នេះការអនុវត្ត ’TIP’ មាន់កំពុងលូតលាស់នេះ កសិករដៃគូរក៏អាចជ្រើសរើសតាមលក្ខណៈថៃដន្យ ។ ជាទូទៅកសិករចិញ្ចឹមមាន់មេ ដើម្បីផលិតកូនសម្រាប់ចិញ្ចឹមជាមាន់សាច់ ដូច្នេះហើយជាចាំបាច់ត្រូវជ្រើសរើសកសិករដែលមានចិត្តចង់ចូលរួម ។ ការធ្វើបង្ហាញអាចធ្វើឡើងនៅលើ ៥-១០កន្លែងក្នុងភូមិ អាស្រ័យទៅតាមចំនួនប្រជាជនក្នុងភូមិ នោះ ។ ទោះបីយ៉ាងណាក៏ដោយ ក៏កសិករចូលរួមត្រូវមានកិច្ចសន្យាធ្វើការជាមួយកសិករ ៥នាក់ទៀត ។ អ្នកផ្សព្វផ្សាយអាចធ្វើការជាមួយក្រុមនោះ មួយសប្តាហ៍ម្តងដើម្បីត្រួតពិនិត្យការធ្វើបង្ហាញ និងពិភាក្សាបញ្ហាទៅលើការអនុវត្តន៍ ’TIP’ នេះ ។

វិធីសាស្ត្រសម្រាប់ការអនុវត្តន៍ ’TIP’ នេះ ផ្អែកលើការធ្វើបង្ហាញតាមគោលដៅគ្រួសារនិមួយៗ ប៉ុន្តែការជួបប្រជុំ និងពិភាក្សារៀងរាល់សប្តាហ៍ ត្រូវធ្វើជាក្រុមធំនៅក្នុងភូមិដែលមាន ការចូលរួមទាំងកសិករធ្វើបង្ហាញ និងដៃគូរបស់គេ ។

ដ្យាក្រាមនៃយុទ្ធសាស្ត្ររីកសាយលើការងារផ្សព្វផ្សាយនៃ TIP នេះ



| | |
|---|---|
| **ដំណាក់កាល និងការណែនាំ** | ដំណាក់កាល និងបែបបទនានាក្នុងការរៀបចំ អនុវត្ត និង វាយតម្លៃទៅលើ 'TIP' នេះ មានរៀបចំក្បោះក្បាយនៅខាងក្រោម ៖ |

<u>ការជ្រើសរើសទីតាំង</u>

ដោយសារតែ 'TIP' នេះអាចសមស្របស្ទើរតែគ្រប់តំបន់ទាំងអស់នៃប្រទេសកម្ពុជា ដូច្នេះមិនមានជាលក្ខណៈវិនិច្ឆ័យអ្វីធំដុំសម្រាប់ការជ្រើសរើសនោះឡើយ ។ ទោះបីយ៉ាងនេះក៏ដោយ ភូមិដែលមានផ្ទះនៅ ដាច់ៗឆ្ងាយពីគ្នា គួរត្រូវបានជ្រើសរើសដើម្បីសាកល្បង 'TIP' នេះ ជាដំបូងសិន ដើម្បីងាយស្រួលក្នុង ការរៀបចំ និងទីកន្លែង សម្រាប់ផលិតចំណីមាន់ទៀតផង ។

<u>ការជ្រើសរើសកសិករ និងការរៀបចំ</u>

ដើម្បីធ្វើឱ្យតម្លៃ ការងារផ្សព្វផ្សាយនេះ អាចទទួលយកបាន និងបង្កើនប្រសិទ្ធិភាពនៃការប្រើធនធាននោះ ភ្នាក់ងារផ្សព្វផ្សាយគួរ ៖

- ជ្រើសរើសកសិករចាប់អារម្មណ៍ និងសកម្ម ៥-១០នាក់ នៅក្នុងភូមិមួយ (ចំនួនអាស្រ័យលើចំនួនគ្រួសារ ដង់ស៊ីតេនិងទំហំភូមិ) ។កសិករចូលរួមត្រូវមានមេមាន់យ៉ាងហោចណាស់៥ក្បាលសម្រាប់ចូលរួមអនុវត្ត 'TIP' នេះ ដែលអាចផលិតកូនមាន់ ២០០ ក្បាលក្នុងមួយឆ្នាំ ។
- កសិករដែលបានជ្រើសរើសមានផ្ទះនៅឆ្ងាយៗពីគ្នានៅក្នុងភូមិ ដើម្បីធ្វើឱ្យការផ្សព្វផ្សាយចែកចាយដល់មនុស្សច្រើន ។ កសិករចូលរួមធ្លាប់មានបទពិសោធន៍លើការចិញ្ចឹមមាន់ខ្លះ និងមានចិត្តចង់ចូលរួម ។
- ជាលក្ខខណ្ឌសម្រាប់ចូលរួមនៅក្នុងការអនុវត្តន៍ 'TIP' នេះ កសិករដែលបានជ្រើសរើសត្រូវរកដៃគូរចំនួន ៥នាក់ ដែលរស់នៅជុំវិញផ្ទះខ្លួនដើម្បីធ្វើការរៀនសូត្ររួមគ្នា ។
- ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់កសិករជ្រើសរើស និងចែករំលែកបទពិសោធន៍ដល់អ្នកដទៃ មាន សំភារៈមួយ ចំនួនដែលផ្តល់ឱ្យកសិករដូចជាសមាសធាតុចំណីដែលគាត់ មិនអាចផលិតនៅក្នុងភូមិ និង ពូជដំណាំជាចំណីប្រូតេអ៊ីន ឬប្លាស្ទិកសម្រាប់ផលិតចកបាយទា ក្នុងករណីលក្ខខណ្ឌអំណោយផល និង វ៉ាក់សាំង ប៉ុន្តែកសិករត្រូវមានមេមាន់ សំភារៈសម្រាប់ធ្វើទ្រុង របងបាំង និងដី ។

<u>ឧបករណ៍/សំភារ</u>

សំភារៈដែលមិនមាននៅក្នុងភូមិ ឬមិនអាចផលិតបានដោយកសិករ អាចត្រូវផ្តល់ឱ្យជាការលើក ទឹកចិត្តដើម្បីចូលរួម និងចែករំលែកបទពិសោធន៍ដល់អ្នកដទៃ ។ សំភារៈ និង ឧបករណ៍ត្រូវការសម្រាប់អនុុវត្ត 'TIP' នេះមាន ៖

សំភារៈឧបត្ថម្ភដល់កសិករ

- វ៉ាក់សាំងសម្រាប់កូនមាន់ (ដង្កោរ និងអុតមាន់) សម្រាប់ការ ធ្វើវ៉ាក់សាំងដំបូងប៉ុណ្ណោះ ។
- កំរាលប្លាស្ទិកប្រសិនបើកសិករត្រូវការផលិតចកបាយទា ។
- ចំណីប្រូតេអ៊ីនដែលកសិករមិនអាចផលិតបានដោយខ្លួនឯង (ផ្តល់លើកដំបូងជាការលើកទឹកចិត្ត) ។
- គ្រាប់ពូជដំណាំចំណីសត្វរួមបញ្ចូលទាំងជន្លេន ប្រសិនបើ មានតម្រូវការ ។

ចំណាំ

- ក្នុងការអនុវត្តន៍ 'TIP' នេះ ដែលមានកសិករច្រើនចាប់អារម្មណ៍នោះ ចំណាយផ្សេងៗត្រូវចេញ ដោយកសិករ រួមទាំងតម្លៃសេវាកម្ម ក្រោយពីការធ្វើបង្ហាញម្តង ។
- ភ្នាក់ងារផ្សព្វផ្សាយនៅពេលនោះ អាចធ្វើការជាមួយភ្នាក់ងារពេទ្យសត្វភូមិ ប្រសិនបើមានដើម្បីជួយ សំរួលដល់ការអនុវត្តន៍ 'TIP' នេះ ។
- ជាទូទៅ កសិករមិនមានប្រាក់សម្រាប់បង់ដល់សេវាកម្ម របស់ភ្នាក់ងារផ្សព្វផ្សាយ ក៏ដូចជាពេទ្យសត្វភូមិដែរ ដូច្នេះភាគី ទាំងសងខាងត្រូវរៀបចំជាកិច្ចព្រមព្រៀង ដោយយកថ្លៃ សេវាកម្ម បូក ថ្លៃវ៉ាក់សាំង ពី ១០-១៥ភាគរយ លើចំនួនមាន់ផលិតបាន ។ ធ្វើតាមវិធីនេះ អាចលើកទឹកចិត្តទាំងកសិករ ភ្នាក់ងារផ្សព្វផ្សាយ និងពេទ្យសត្វភូមិ អនុវត្តឱ្យល្អដើម្បី ចែកចាយផលប្រយោជន៍គ្នា ។

ការចូលរួមចំណែកពីកសិករ

- រៀបចំដីមួយផ្នែកសម្រាប់អនុវត្ត 'TIP' នេះ ។
- មានមេមាន់ ៥ក្បាល សម្រាប់អនុវត្ត 'TIP' នេះ ។
- សំភារៈសម្រាប់សាងសង់ទ្រុង អង្រុតក្រុង និងរបងបិទបាំង ។
- សមាជិកគ្រួសារម្នាក់ទទួលខុសត្រូវលើការងារនេះ រួមបញ្ចូលទាំងការចូលរួមនៅក្នុងកិច្ចប្រជុំ និងពិភាក្សាគ្នានានា ។
- ចំណីមាន់ មាន ចុងអង្ករ និងកន្ទក់ដើម្បីផ្សំចំណីតាមរូបមន្ត ខាងលើ ។

ការពិនិត្យតាមដាន និងវាយតម្លៃ

ដោយរយៈពេលសម្រាប់ចិញ្ចឹមបំប៉នមានរយៈ ៣-៥ ខែ ភ្នាក់ងារផ្សព្វផ្សាយ ត្រូវចុះជួបកសិករដល់ទីកន្លែង ក្នុងមួយសប្តាហ៍ម្តង ។ តួនាទី អ្នកផ្សព្វផ្សាយដែលត្រូវធ្វើមានដូចខាងក្រោម ៖

- រៀបចំការប្រជុំជាមួយកសិករ និងដៃគូរបស់ពួកគេ ដើម្បីពិភាក្សាលើដំណើរការបង្ហាញអាស្រ័យ ទៅតាមជម្រើសបច្ចេក ទេសដែលកសិករបានជ្រើស ។
- ត្រួតពិនិត្យតាមដាននៅតាមផ្ទះនិមួយៗដើម្បីវាយតម្លៃទៅលើការអនុវត្តន៍ 'TIP' នេះ ។
- ថ្លឹងកូនមាន់ជាក្រុមរៀងរាល់ ៧-១០ ថ្ងៃម្តងជាមួយម្ចាស់ ។
- រៀបចំការត្រួតពិនិត្យតាមដាន និងវាយតម្លៃដោយមានការចូលរួមពីកសិករនៅពេលកូនមាន់ដល់អាយុសម្រាប់លក់ចេញទៅទីផ្សារ ។ នៅថ្ងៃជាមួយគ្នានេះ ភ្នាក់ងារផ្សព្វផ្សាយអាចអញ្ជើញកសិករផ្សេងៗ ទៀតឱ្យចូលរួមវាយតម្លៃ 'TIP' នេះ និងទន្ទឹមគ្នានោះរៀបចំទិវាស្រែកសិករដែលអនុញ្ញាត ឱ្យកសិករ បង្គោលចែករំលែក បទពិសោធន៍ដល់អ្នកដទៃ ។

<u>ផែនការ</u>

ចំពោះ 'TIP' នេះ មិនមានពេលវេលា/រដូវជាក់លាក់ចាំបាច់នោះទេ តែជាការប្រសើរគួរតែចាប់ អនុវត្តក្រោយ ភ្លៀងធ្លាក់ជោគជាំនៅដើមរដូវវស្សា (ជម្ងឺដង្កោរអាចផ្ទុះឡើង នៅពេលភ្លៀងតិចៗដំបូង) ហើយតំបន់លិចទឹកនៅរដូវវស្សា គួរចាប់ផ្តើម ក្រោយទឹកសំរក (វិច្ឆិកា-ធ្នូ) ។

### ៣.២ ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្តែងនៃសាម៉ីអង្គភាព ។ តារាងថវិកា ខាងក្រោមបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ដោយយោងទៅលើការប៉ាន់ស្មានលើបទដ្ឋានអនុវត្ត បច្ចេកវិទ្យា របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម។

| **ថវិកា និង ការសន្មត់** | ចំនួន / តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ៣០ នាក់ |
| ទុនសម្រាប់ទីតាំងធ្វើបង្ហាញ (ខ) | $២៨០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (គ)<br>- ឯកសារ / ការណែនាំពីបច្ចេកវិទ្យា TIP | $៣០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (ឃ)<br>- អាហារសំរ៉ន់ | $៩០ |
| ទុនចូលរួមពីកសិករគំរូ (ង) | កំលាំងពលកម្ម មេមាន់ / កូនមាន់ |

| | |
|---|---|
| | ពេទ្យសត្វភូមិ |
| ទិវាស្រែ - អាហារសំរ៉ន់ (ច) | $២៥ |
| ទិវាស្រែ - សំភារៈ (ឆ) | $១០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ជ)<br>- ការបណ្តុះបណ្តាល, ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $៤២ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ឈ) | $២៤ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេស (ញ) | $២០ |
| សរុប | $៥២១ |

**ការសន្មត់ប្រើប្រាស់មាន**

ក. ក្នុង TIP មួយ មានក្រុមកសិករ (៣០ នាក់) និង ទីកន្លែងធ្វើបង្ហាញ ២ កន្លែង

ខ. ទុនសម្រាប់ធ្វើបង្ហាញពីការចិញ្ចឹមមាន់យកសាច់ ១២០ថ្ងៃ / វគ្គ រួមមាន ទ្រុងមាន់ =១០០ដុល្លា ចំណី១ដុល្លា សម្រាប់មាន់១ក្បាល =១៤០ដុល្លា ទុនសម្រាប់ធ្វើបង្ហាញពីរកន្លែងនេះ = ២៨០ ដុល្លា

គ. ឯកសារបណ្តុះបណ្តាលបច្ចេកវិទ្យាមានរួមបញ្ចូលទាំងសំភារៈសម្រាប់បង្រៀន មេរៀន ការបញ្ចាំងស្លាយ និង ផ្ទាំងរូបភាពធំៗ ដែលជាដំណើរការនៃវិធីសាស្ត្របង្រៀន ។

ឃ. ការបណ្តុះបណ្តាលក្រុមកសិករមាន ៣វគ្គ មួយវគ្គ មានរយៈពេលមួយថ្ងៃ លើកលែងតែវគ្គ ការធ្វើជី កំប៉ុស្តិ៍ មានតែ ២វគ្គទេ និង ការកំណត់ចំណាត់ថ្នាក់ដី មានមួយវគ្គ

ង. ទុនចូលរួមពីកសិករឬទីកន្លែងបង្ហាញ មួយកន្លែង មានមាន់៤០ ដែលបានចាក់វ៉ាក់សាំងរួច សួនបន្លែសម្រាប់ចំណីមាន់ កំលាំងពលកម្ម និង ថ្លៃសេវាកម្មសម្រាប់ពេទ្យសត្វភូមិ

ច. ទិវាស្រែមានកន្លះថ្ងៃ មានតែម្តងក្នុងវគ្គណាមួយក្នុងចំណោមទាំងបីវគ្គ និងអាចមានការចូលរួមពីកសិករ នៅក្បែរៗភូមិប្រហែល ៤០-៦០នាក់

ឆ. សំភារៈសម្រាប់ទិវាស្រែរួមមាន ឧឃោសនស័ព្ទ(មេក្រូ) ផ្ទាំងក្រដាសប្លាស្ទិក និងផ្ទាំងបដារូបភាពផ្សេងៗ

ជ. សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន៤ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងបង្ហាញ, ការចាប់ផ្តើម , ការត្រួតពិនិត្យតាមដាន ។ ចំពោះការបណ្តុះបណ្តាលសម្រាប់ ៣វគ្គ ផ្តល់អោយ ៦ ថ្ងៃ និងទិវាស្រែផ្តល់ អោយ២ថ្ងៃ

ឈ. ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ១២ថ្ងៃ

ញ. មន្ទីរកសិកម្មខេត្ត-អ្នកឯកទេសផ្តល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្តុះបណ្តាល TIP

| សកម្មភាព | ឯកតា | ក) បរិមាណ | ខ) តម្លៃ/ឯកតា | តម្លៃ (កXខ) |
|---|---|---|---|---|
| ការជ្រើសរើសកសិករចូលរួម | ថ្ងៃ | ១ | | |
| រៀបចំសម្រាប់ចាប់ផ្តើម | ថ្ងៃ | ៣ | | |
| ធ្វើបង្ហាញរួមបញ្ចូលទាំងការជួបប្រជុំ កសិករម្នាក់ៗ និងជាក្រុម និងការ ពិនិត្យតាមដាន-វាយតម្លៃ | ថ្ងៃ | ១២ | | |
| ទិវាស្រែកសិករ និងទស្សនះកិច្ច | ថ្ងៃ | ១ | | |
| ផ្សេងៗ | ថ្ងៃ | ២ | | |
| សរុប | | ១៩ | | |

*ចំនួនថ្ងៃនេះប៉ាន់ស្មានសម្រាប់ការអនុវត្ត សម្រាប់កសិករមួយក្រុមដែលមានមនុស្សប្រមាណ ២៥-៥០ (ចំនួនកសិករនេះ មានកសិករ ជ្រើសរើសសម្រាប់ធ្វើបង្ហាញ និងកសិករដៃគូរ) ការធ្វើបង្ហាញ ៥-១០ កន្លែង ។ កសិករអាចមកពីភូមិ ១-២ អាស្រ័យទៅតាមទីតាំង ។ ប្រសិនបើភូមិនៅក្បែរគ្នា ការប្រជុំអាចរៀបនៅមួយកន្លែងបាន ។

### ៣.៣ កន្លែងរកឯកសារបន្ថែម

មជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម “សែលអាគ្រិត “ និងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ។

### ៣.៤ យែនឌ័រ

ស្ត្រីសមរម្យសម្រាប់ជ្រើសរើសក្នុងការចូលរួមនៅក្នុង ’TIP’ នេះណាស់ ដោយសារជាទូទៅពួក គេច្រើនធ្វើការងារនៅក្បែរផ្ទះ។ ’TIP’នេះអាចជួយស្ត្រីឱ្យបង្កើនចំណូល ដើម្បីគាំទ្រដល់គ្រួសារគេជាពិសេសសម្រាប់បង្កើនអាហាររូបត្ថម្ភដល់កុមារ និងទិញសំភារៈសម្រាប់កូនទៅសាលារៀន ។

ដោយសារអ្នកចូលរួមអនុវត្ត ’TIP’ នេះ ភាគច្រើនជាស្ត្រី ការផ្តល់អទិភាពដល់អ្នកផ្សព្វផ្សាយជា ស្ត្រីក្នុងការរៀបចំការងារនេះនៅតាមភូមិ មានសារៈសំខាន់ណាស់ ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ២០០ វិថីព្រះនរោត្តម ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: ០១២ ៨៣៣ ៧៧៧ ឬ ០១២ ៨២៦ ៦១៧

ទូរសារ: ៨៥៥ ២៣ ២១០ ៩៤៨ ឬ ៨៥៥ ២៣ ២១៣ ០១១

អ៊ីម៉ែល: kunso@camnet.com.kh ឬ mak_soeun@camnet.com.kh

នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម (Department of Agricultural Extension)

---

បោះពុម្ពលើកទី១ ៣០០ច្បាប់